**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## សារណាបញ្ចប់ការសិក្សា

# ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុ លើសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ឡាយ ឧត្តម**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត ឌុយ ចាន់ឌីណា**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី ០៤

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ឡាយ ឧត្តម** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី០៤ ក្រុម $D_4C_1$ ឆ្នាំសិក្សា ២០១៩-២០២០ នៃសាលកវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

១. លោកឪពុក **ឡាយ គឹមសាន** និងអ្នកម្តាយ **ស្រេង មុំ** ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងចិញ្ចឹមបីបាច់ថែរក្សា រួមទាំងផ្គត់ផ្គង់ការសិក្សាតាំងពីថ្នាក់បឋមសិក្សារហូតបានថ្នាក់មហាវិទ្យាល័យ។

២. ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងមន្ត្រីរាជការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងបង្រៀន និងណែនាំដល់រូបខ្ញុំបាទ។

៣. លោកសាស្ត្រាចារ្យណែនាំ **បណ្ឌិត ឌុយ ចាន់ឌីណា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃដើម្បីពិនិត្យ ផ្តល់យោបល់ និងកែតម្រូវចំណុចខ្វះខាត តាំងពីចំណុចសេចក្តីផ្តើម ដល់សេចក្តីបញ្ចប់។

៤. រាមច្បង អ្នកសិក្សាស្រាវជ្រាវទាំងអស់ដែលបានបន្សល់ទុកនូវឯកសារស្រាវជ្រាវ និងអត្ថបទវិចារណកថាជាច្រើនទៀតដែលបានផ្តល់ជាទុនគំនិតឲ្យខ្ញុំ នៅក្នុងការសិក្សា និងស្រាវជ្រាវនេះ។

៥. មិត្តភក្តិ និងមិត្តរួមថ្នាក់ ដែលតែងតែផ្តល់ជាគំនិត និងផ្តោះផ្តង់យោបល់គ្នាកន្លងមក។

ជាចុងក្រោយ ខ្ញុំបាទសូមគោរពជូនពរដល់លោកឪពុក និងអ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យបង្រៀន និងណែនាំ រាមច្បង និងមិត្តភក្តិទាំងអស់ ឲ្យជួបតែសំណាងល្អ សុខសុភមង្គល និងជួបតែពុទ្ធិពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ៕

# អារម្ភកថា

បន្ទាប់ពីចំណាយពេល៤ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមក ខ្ញុំពិតជាទទួលបាននូវចំណេះដឹងយ៉ាងច្រើនពីសាស្ត្រាចារ្យដែលបានបង្ហាត់បង្រៀនផ្នែកសេដ្ឋកិច្ច និងនយោបាយ។ នៅក្នុងពេលសិក្សា អ្វីដែលធ្វើឲ្យខ្ញុំមានការចាប់អារម្មណ៍ជាងគេ នោះគឺការប្រព្រឹត្តទៅនៃនយោបាយសារពើពន្ធ និងជាពិសេសគឺគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ដែលជាចំណុចសំខាន់នៅក្នុងការជួយសេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើន។ អាស្រ័យហេតុនេះ ទើបខ្ញុំសម្រេចចិត្តសាកល្បងសិក្សាស្រាវជ្រាវលើប្រធានបទនេះ "**ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុលើសេដ្ឋកិច្ចកម្ពុជា**" ដោយពិនិត្យមើលទិដ្ឋិភាពទ្រឹស្តី និងការអនុវត្តជាក់ស្តែង។

ជាការពិត ប្រទេសកម្ពុជាជាប្រទេសដែលទើបតែងើបចេញពីភ្នក់ភ្លើងសង្គ្រាមដែលស្ទើរតែបានបំផ្លាញអ្វីៗគ្រប់យ៉ាងអស់ទៅហើយនៅក្នុងប្រទេសមួយនេះ។ ដោយឡែកសេដ្ឋកិច្ចកម្ពុជា ទើបតែទទួលបាននូវការរីកចម្រើនគួរឲ្យកត់សម្គាល់នៅក្នុងរយៈកាល១ទសវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ ដែលអ្វីៗនៅមិនទាន់មានភាពរឹងមាំនៅឡើយ។ ចំណេរតទៅ មានតែការខិតខំប្រឹងប្រែង សាមគ្គីគ្នា ការបង្កើនធនធានមនុស្ស និងបង្កើនឯករាជ្យភាពនៃគោលនយោបាយនានា ជាពិសេសគោលនយោបាយរូបិយវត្ថុ ដែលច្រើនតែពឹងផ្អែកលើសេដ្ឋកិច្ចបរទេស ទើបជាផ្លូវដែលអាចឲ្យកម្ពុជាទទួលបាននូវការរីកចម្រើនដ៏ពេញលេញមួយ។

ខ្ញុំសង្ឃឹមថា ឯកសារស្រាវជ្រាវមួយនេះ នឹងក្លាយជាឯកសារដែលផ្តល់ផលប្រយោជន៍ដល់មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវក្រោយៗក្នុងការសិក្សាបន្តទៀត។

បើទោះបីជាខ្ញុំ ខិតខំពិនិត្យពិច័យល្អិតល្អន់យ៉ាងណាក៏ដោយ ក៏ប្រហែលជាឯកសារនេះនៅមានចំណុចខ្វះខាត ឬខុសអក្ខរាវិរុទ្ធ និងមិនច្បាស់អត្ថន័យត្រង់ណាមួយជាពុំខាន។ អាស្រ័យហេតុនេះ សូមអ្នកអាន អ្នកសិក្សា មេត្តាអធ្យាស្រ័យដល់ខ្ញុំបាទផង។ ខ្ញុំបាទសូមទទួលរាល់ការរិះគន់ក្នុងន័យស្ថាបនាទាំងអស់ដើម្បីឲ្យឯកសារស្រាវជ្រាវនេះកាន់តែមានភាពច្បាស់ការ។

# មាតិកា

បញ្ជីតារាង ....... iv

បញ្ជីក្រាហ្វ ....... v

បញ្ជីរូបភាព ....... vi

បញ្ជីប្រអប់ ....... vii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ....... ១

២. ចំណោទបញ្ហា ....... ២

៣. គោលបំណងនៃការស្រាវជ្រាវ ....... ៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ....... ៣

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ....... ៣

៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ ....... ៤

ក. ប្រភពទិន្នន័យ ....... ៤

ខ. ការវិភាគទិន្នន័យ ....... ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....... ៤

## ជំពូកទី១៖ រំលឹកទ្រឹស្តី (ទ្រឹស្តីនយោបាយរូបិយវត្ថុ)

១.១. និយមន័យ ....... ៦

១.១.១. គោលនយោបាយរូបិយវត្ថុ ....... ៦

១.១.២. ឧបករណ៍គោលនយោបាយរូបិយវត្ថុ ....... ៦

១.១.២.១. ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយប្រយោល ....... ៧

១.១.២.២. ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយផ្ទាល់ ....... ៨

១.១.៣. ការផ្គត់ផ្គង់រូបិយវត្ថុ (Broad Money) ....... ៩

១.១.៤. អត្រាប្តូរប្រាក់........................................................................................................ ១០

១.១.៥. ផលិតផលក្នុងស្រុកសរុប(GDP)........................................................................... ១១

១.២. ករណីសិក្សាកន្លងមក ........................................................................................ ១១

## ជំពូកទី២៖ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

២.១. ការវិវត្តន៍ថ្មីៗនៃស្ថានភាពសេដ្ឋកិច្ចកម្ពុជា ..................................................................... ១៥

២.១.១. ផលិតផលក្នុងស្រុកសរុប(GDP) .......................................................................... ១៦

២.១.១.១. ផលិតផលក្នុងស្រុកក្នុងប្រជាជនម្នាក់ៗ(GDP Per Capita).......................................១៧

២.១.២. ពាណិជ្ជកម្មអន្តរជាតិ ......................................................................................... ១៨

២.១.២.១. ការនាំចូល ....................................................................................................... ១៩

២.១.២.២. ការនាំចេញ.......................................................................................................២០

២.១.៣. ការវិនិយោគ ...................................................................................................... ២២

២.១.៤. ការចំណាយសាធារណៈ........................................................................................ ២៣

## ជំពូកទី៣៖ ស្ថានភាពគោលនយោបាយរូបិយវត្ថុនៅកម្ពុជា

៣.១. ស្ថានភាពទូទៅនៃគោលនយោបាយរូបិយវត្ថុនៅកម្ពុជា..............................................................២៥

៣.២. ការអនុវត្តគោលនយោបាយរូបិយវត្ថុនៅកម្ពុជា.................................................................. ២៧

២.២.១. គណៈកម្មការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុ.............................................................២៨

២.២.២. ឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ..................................................២៨

២.២.២.១. គោលនយោបាយអត្រាប្តូរប្រាក់..............................................................................២៩

២.២.២.២. ប្រាក់បម្រុងកាតព្វកិច្ច........................................................................................៣១

២.២.២.៣. កម្ចីអប្បហារ ......................................................................................................៣១

២.២.២.៤. មូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា(NCD)..................................... ៣២

## ជំពូកទី៤៖ ការសិក្សាលើការវិភាគ និងបកស្រាយលទ្ធផល


៤.១. លទ្ធផលនៃការស្រាវជ្រាវ ........................................................................................ ៣៥

៤.២. ការបកស្រាយលទ្ធផល ........................................................................................ ៣៩


## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍


១. សេចក្ដីសន្និដ្ឋាន ........................................................................................ ៤១

២. អនុសាសន៍ ........................................................................................ ៤៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាងទី១៖ បង្ហាញពីទំហំវិនិយោគក្នុងស្រុក និងផ្ទាល់ពីបរទេស ........................................................ ២២

តារាងទី២៖ ទិន្នន័យដែលត្រូវធ្វើការសិក្សា និងវិភាគពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៨....................................៣៥

តារាងទី៣៖ ការពិពណ៌នាស្ថិតិ/Descriptive Statistics....................................................................៣៦

តារាងទី៤៖ ការបង្ហាញពីទំនាក់ទំនងនៃអថេរនីមួយៗ/Correlations ....................................................៣៦

តារាងទី៥៖ បង្ហាញពី Model Summary ......................................................................................... ៣៧

តារាងទី៦៖ ការបង្ហាញពីតារាងANOVA[a]..........................................................................................៣៨

តារាងទី៧៖ បង្ហាញពីការព្យាករណ៍/Coefficients[a] ..............................................................................៣៨

# បញ្ជីក្រាហ្វ

ក្រាហ្វទី១៖ បង្ហាញពីការនិន្នាការនៃការកើនឡើងនៃផលិតផលក្នុងស្រុកសរុបពិតរបស់កម្ពុជា (២០០៩ដល់ ២០១៨) ............ ១៧

ក្រាហ្វទី២៖ បង្ហាញពីការកើនឡើងនៃផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនម្នាក់ៗ(GDP Per Capita) នៅកម្ពុជា(២០០៩ដល់២០១៨) ............ ១៨

ក្រាហ្វទី៣៖ បង្ហាញពីទំហំពាណិជ្ជកម្ម និងការនាំចេញ ចូលរបស់កម្ពុជាពីឆ្នាំ២០០៩ ដល់២០១៨............ ១៩

ក្រាហ្វទី៤៖ បង្ហាញពីការទំហំនៃកានាំចូលរបស់កម្ពុជានៅចន្លោះឆ្នាំ២០០៩ដល់២០១៨............ ២០

ក្រាហ្វទី៥៖ បង្ហាញពីការទំហំនៃកានាំចេញរបស់កម្ពុជានៅចន្លោះឆ្នាំ២០០៩ដល់២០១៨............ ២០

## បញ្ជីរូបភាព

រូបភាពទី១៖ បង្ហាញពីសូចនាករថវិកាជាតិសំខាន់ៗពីឆ្នាំ២០១៧ ដល់២០១៩......................................២៤

រូបភាពទី២៖ បង្ហាញពីស្ថានភាពនៃរូបិយវត្ថុទូទៅ និងដុល្លាររូបនីយកម្ម...............................................២៦

រូបភាពទី៣៖ បង្ហាញពីស្ថានភាពបញ្ញើជាជៀល និងឥណទានចំពោះវិស័យឯកជន ................................ ២៧

រូបភាពទី៤៖ បង្ហាញពីការឡើងចុះនៃអត្រាប្តូរប្រាក់ និងអត្រាអតិផរណាពីឆ្នាំ២០១០ ដល់២០២០............៣០

# បញ្ជីប្រអប់

ប្រអប់ទី១៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុលើសេដ្ឋកិច្ចកម្ពុជា..............................១២

ប្រអប់ទី២៖ ករណីសិក្សាពីឥទ្ធិពលនៃអត្រាប្តូរប្រាក់លើកំណើនសេដ្ឋកិច្ចកម្ពុជា....................................១៣

ប្រអប់ទី៣៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុក្នុងប្រទេសសិរីលង្កា...........................១៣

ប្រអប់ទី៤៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុនៅប្រទេសប៉ាគីស្ថាន ........................... ១៤

ប្រអប់ទី៥៖ ទំហំពាណិជ្ជកម្មរបស់កម្ពុជា នៅឆ្នាំ២០១៨ មានទឹកប្រាក់ជិត២៥ពាន់លានដុល្លារ, ការនាំចេញ ជាង១១ពាន់លានដុល្លារ និងនាំចូលវិញជាង១៣ពាន់លានដុល្លារ....................................២១

ប្រអប់ទី៦៖ ស្ថានភាពទូទៅនៃគោលនយោបាយរូបិយវត្ថុនៅកម្ពុជា....................................................២៥

ប្រអប់ទី៧៖ NCD ត្រូវបានដាក់ឲ្យទិញ-លក់រវាងគ្រឹះស្ថានហិរញ្ញវត្ថុ ..................................................៣៣

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថា ជាប្រទេសមួយដែលមានការអភិវឌ្ឍលឿនមួយនៅក្នុងពិភពលោក ជាមួយនឹងល្បឿនសេដ្ឋកិច្ចក្នុងរង្វង់អត្រាប្រមាណជា៧%ក្នុងមួយឆ្នាំ។ យោងតាមការចុះផ្សាយរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) បានបង្ហាញថា នៅក្នុងឆ្នាំ២០១៨ កំណើនសេដ្ឋកិច្ចកម្ពុជាមានអត្រា៧.៥% និងតាមការព្យាករណ៍សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៩មានអត្រាប្រហែល៧%។ បើនិយាយពីកត្តាដែលធ្វើឲ្យសេដ្ឋកិច្ចកម្ពុជា ត្រូវបានគេវាយតម្លៃថា មានលក្ខណៈរឹងមាំ និងទទួលបានការរីកចម្រើនយ៉ាងឆាប់រហ័សនេះ គឺមានការចូលរួមពីកត្តាជាច្រើន ដូចជា ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុប និងប្រទេសនានា មានភាពនឹងនរ ការកម្រើកឡើងនៃសហគ្រាសធុនតូច និងមធ្យម ការវិនិយោគផ្ទាល់ពីបរទេស ការសម្រេចបាននូវគោលដៅទេសចរណ៍បរទេស ការរីកចម្រើនផ្នែកសំណង់ រួមទាំងការរក្សាស្ថេរភាពថ្លៃ និងអត្រាប្តូរប្រាក់ជាដើម[1]។ កត្តាទាំងអស់នេះ ត្រូវបានគាំទ្រយ៉ាងពេញទំហឹង ពីគោលនយោបាយចំនួនពីរៈ ទី១ គឺគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ និងទី២ គឺគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលកម្ពុជា ដែលមានភាពច្បាស់លាស់ និងទន់ភ្លន់។ សម្រាប់គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៅកម្ពុជា ត្រូវបានពឹងផ្អែកច្រើនទៅលើឧបករណ៍ចំនួន៣ៈ ទីមួយ គឺការអន្តរាគមន៍ទៅលើអត្រាប្តូរប្រាក់ ទីពីរ ការគ្រប់គ្រងបរិមាណរូបិយវត្ថុរួមក្នុងទីផ្សារតាមរយៈទុនបម្រុងកាតព្វកិច្ច និងទីបី តាមរយៈប្រតិបត្តិការទីផ្សារចំហរដែលមានកម្រិតតិចតួចនៅឡើយ។

យ៉ាងណាមិញ នៅក្នុងឆ្នាំ២០១៨ការផ្គត់ផ្គង់រូបិយវត្ថុទូទៅ(M2)មានកំណើន២៤.២% ខ្ពស់ជាងកំណើនឆ្នាំមុនបន្តិច(២៣.៨%) និងកំណើនមធ្យមប្រចាំឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ(២២%)។ កំណើនរូបិយវត្ថុទូទៅ នេះបន្តមានកម្រិតសមស្របនឹងការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច និងមិនបានបណ្តាលឲ្យមានសម្ពាធលើ អត្រាអតិផរណា និងអត្រាប្តូរប្រាក់ឡើយ។ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិករក្សាបាននូវអត្រាក្នុងរង្វង់៤,០៥០រៀលក្នុងមួយដុល្លារអាមេរិក ដែលបណ្តាលមកពីបរិការណ៍ដែលរូបិយបណ្ណ

[1] Ly, Sodeth; Sanchez Martin, Miguel Eduardo; Phim, Runsinarith; Ky, Linna; Tong, Kimsun; Provo, Anne Marie; Nagpal, Somil; Vashakmadze, Ekaterine T: Cambodia Economic Update: Recent Economic Developments and Outlook (WB, English) 2019 [http://documents.worldbank.org/curated/en/843251556908260855/Cambodia-Economic-Update-Recent-Economic-Developments-and-Outlook] (អានថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩)

របស់ប្រទេសមួយចំនួនកំពុងទទួលរងសម្ពាធពីការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក និងដោយសារការផ្គត់ផ្គង់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជាមានកម្រិតស្របនឹងការកើនឡើងតម្រូវការប្រាក់រៀល តាមរយៈការទិញកសិផល និងការបង់ពន្ធ[2]។

ទោះបីជាយ៉ាងណាក៏ដោយ ការដាក់ចេញនូវនយោបាយរូបិយវត្ថុ និងសារពើពន្ធរបស់រដ្ឋាភិបាលកម្ពុជា គឺជាមូលហេតុចម្បងនៅក្នុងការកសាងកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនេះ។ ធនាគារជាតិនៃកម្ពុជាគឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងការតាក់តែង និងអនុវត្តគោលនយោបាយរូបិយវត្ថុដែលសំដៅរក្សាស្ថិរភាពថ្លៃ និងកម្រិតនៃអត្រាអតិផរណា ដែលត្រូវធ្វើយ៉ាងណាឲ្យស្ថិតនៅក្នុងកម្រិតទាបក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥%។ ប៉ុន្តែការអនុវត្តគោលនយោបាយរូបិយវត្ថុនៅកម្ពុជាគឺនៅមានកម្រិតនៅឡើយ[3] ដោយសារតែបរិការណ៍សេដ្ឋកិច្ចកម្ពុជាស្ថិតនៅក្នុងកម្រិតដុល្លារូបនីយកម្ម[4]ខ្ពស់នៅឡើយដែរ។ ដើម្បីអាចឲ្យប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជាកាន់តែមានភាពល្អប្រសើរ លុះត្រាតែកម្រិតនៃដុល្លារូបនីយកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជាមានកម្រិតកាន់តែទាបទៅៗ ហើយការប្រើប្រាស់ប្រាក់រៀលដែលជារូបិយវត្ថុជាតិកាន់តែទូលំទូលាយជាងមុន ជាពិសេសនៅក្នុងប្រតិបត្តិការដោះដូរតូចៗ។

## ២. ចំណោទបញ្ហា

ដោយមើលឃើញពីសារៈសំខាន់នៃគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ចំពោះការកសាងកំណើនសេដ្ឋកិច្ចជាតិ ដូច្នេះវាចាំបាច់ណាស់នៅក្នុងការសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុទៅលើសេដ្ឋកិច្ចកម្ពុជា រួមទាំងការប្រើប្រាស់នូវឧបករណ៍រូបិយវត្ថុរបស់ធនាគារជាតិបានជះឥទ្ធិពលកម្រិតណាទៅលើការកសាងកំណើនសេដ្ឋកិច្ចកម្ពុជានាពេលកន្លងមក។

ចំពោះការសិក្សាពី “**ឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុទៅលើសេដ្ឋកិច្ចកម្ពុជា**” នេះ យើងនឹងធ្វើការបកស្រាយនូវសំនួរសំខាន់ៗដូចខាងក្រោម៖

១. តើគោលនយោបាយរូបិយវត្ថុមានសារៈសំខាន់ដូចម្តេចចំពោះសេដ្ឋកិច្ចកម្ពុជា?

២. តើការផ្គត់ផ្គង់រូបិយវត្ថុទៅក្នុងទីផ្សារមានឥទ្ធិពល និងទំនាក់ទំនងបែបណាចំពោះសេដ្ឋកិច្ចកម្ពុជា?

---

[2] របាយការណ៍ប្រចាំឆ្នាំ២០១៨ របស់ធនាគារជាតិនៃកម្ពុជា (អានថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០)

[3] ទិដ្ឋភាពទូទៅគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា (អានថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០)

[4] លោក Kurt Schuler(Senior Economist to the Chairman, Joint Economic Committee Staff Report Office of the Chairman, Connie Mack) បានឲ្យនិយមន័យដុល្លារូបនីយកម្មថា ជាបាតុភូតដែលប្រជាពលរដ្ឋនៃប្រទេសមួយបានសម្រេចចិត្តជ្រើសរើសប្រើប្រាស់រូបិយប័ណ្ណបរទេស ទូយ៉ាងដូចជាប្រាក់ដុល្លារអាមេរិក ឬរូបិយប័ណ្ណផ្សេងទៀត ជំនួស ឬទន្ទឹមនឹងការប្រើប្រាស់រូបិយវត្ថុជាតិនៃប្រទេសនោះ។(អានថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០)

៣. តើអត្រាប្តូរប្រាក់មានសារៈសំខាន់បែបណា នៅក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជាលើសេដ្ឋកិច្ចកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតលើគោលបំណង៣យ៉ាងធំៗដូចខាងក្រោមៈ

១. សិក្សាពីឥទ្ធិពល និងសារៈសំខាន់នៃគោលនយោបាយរូបិយវត្ថុលើសេដ្ឋកិច្ចកម្ពុជានាពេលកន្លងមក

២. សិក្សាពីស្ថានភាពសេដ្ឋកិច្ចកម្ពុជា

៣. ដើម្បីពន្យល់ពីឥទ្ធិពលរបស់អថេរចំនួន២ដែលមានដូចជា ការផ្គត់ផ្គង់រូបិយវត្ថុ និងអត្រាប្តូរប្រាក់ ដែលជាឧបករណ៍នយោបាយរូបិយវត្ថុដ៏សំខាន់របស់ធនាគារជាតិនៃកម្ពុជា។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះដែនកំណត់នៃការស្រាវជ្រាវលើសារណាបញ្ចប់ការសិក្សានេះ គឺត្រូវបានពិនិត្យមើលទិន្នន័យត្រឹមតែរយៈពេល១០ឆ្នាំ ដែលផ្តោតសំខាន់លើការប្រែប្រួលនៃGDP ពោលគឺចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៨។ ចំពោះវិសាលភាពនៃការស្រាវជ្រាវនេះវិញគឺផ្តោតសំខាន់តែលើចលករដែលមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ចកម្ពុជាចំនួនពីរតែប៉ុណ្ណោះគឺ បរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) និងអត្រាប្តូរប្រាក់(EXC) ដែលនឹងវិភាគត្រឹមតែទំនាក់ទំនង និងភាពសំខាន់របស់វានៅក្នុងការកសាងសេដ្ឋកិច្ចជាតិកម្ពុជាតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

អត្ថបទស្រាវជ្រាវនេះ នឹងផ្តល់ជាប្រយោជន៍ដល់សិស្សនិស្សិតក្នុងការសិក្សាស្វែងយល់បន្ថែម និងកាន់តែស៊ីជម្រៅថែមទៀត នៅក្នុងមុខវិជ្ជាសេដ្ឋកិច្ចហិរញ្ញវត្ថុ ជាពិសេសសិក្សាកាន់តែលម្អិតអំពីគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជាទាំងទ្រឹស្តី និងការអនុវត្តផ្ទាល់។ នៅក្នុងការសិក្សានេះ នឹងមានការពន្យល់លម្អិតអំពីឥទ្ធិពលនៃឧបករណ៍គោលនយោបាយរូបិយវត្ថុ ទៅលើកំណើនសេដ្ឋកិច្ចកម្ពុជានារយៈកាល១ទសវត្សរ៍ចុងក្រោយនេះ រួមទាំងការផ្តល់ជាអនុសាសន៍មួយចំនួនបន្ថែមទៀតដល់រដ្ឋាភិបាល និងធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើឲ្យប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុកាន់តែមានប្រសិទ្ធភាព ក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

### ក. ប្រភពទិន្នន័យ

ឯកសារស្រាវជ្រាវនេះគឺត្រូវបានចងក្រងឡើងដោយប្រើទិន្នន័យកម្រិត២(Secondary Data) ដែលត្រូវបានដកស្រង់ចេញពីប្រភពគេហទំព័រផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ធនាគារពិភពលោក និងអភិវឌ្ឍន៍អាស៊ី បូករួមទាំងឯកសារស្រាវជ្រាវដែលបន្សល់ទុកដោយអ្នកសិក្សាជំនាន់មុនផងដែរ។

### ខ. ការវិភាគទិន្នន័យ

សម្រាប់ការវិភាគទិន្នន័យនៅក្នុងការឯកសារស្រាវជ្រាវនេះ គឺត្រូវបានធ្វើការវិភាគដោយប្រើវិធីសាស្ត្របរិមាណវិស័យ ពោលគឺដោយប្រើប្រាស់វិធីសាស្ត្រ Multiple Regression Model នៅក្នុងកម្មវិធី SPSS ជាជំនួយនៅក្នុងការវិភាគទិន្នន័យ។ ចំពោះ ទិន្នន័យរបស់ផលិតផលក្នុងស្រុកសរុប(GDP) គឺត្រូវបានប្រមូលចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៨ រួមទាំងធ្វើការបកស្រាយទិន្នន័យ បរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) និងអត្រាប្តូរប្រាក់(EXC) ដែលកំណត់យកពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៨ដូចគ្នា ដែលមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចកម្ពុជា ដែលទិន្នន័យទាំងអស់នេះត្រូវបានដកស្រង់ចេញពីទិន្នន័យរបស់ធនាគារពិភពលោក។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកជា៤ជំពូកផ្សេងៗពីគ្នា៖

- **ជំពូកទី១ រំលឹកទ្រឹស្តី (ទ្រឹស្តីនយោបាយរូបិយវត្ថុ)**៖ នៅក្នុងជំពូកនេះ នឹងធ្វើការបង្ហាញពីទ្រឹស្តីនយោបាយរូបិយវត្ថុ ដែលរួមមាននិយមន័យ ឧបករណ៍គោលនយោបាយសំខាន់ៗ រួមទាំងធ្វើការពន្យល់ពីអថេរសំខាន់ៗដែលពាក់ព័ន្ធនឹងការវិភាគ និងក៏បានលើកឡើងពីករណីសិក្សាមួយចំនួនផងដែរ។
- **ជំពូកទី២ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា**៖ នៅជំពូកនេះ បានបង្ហាញពីការវិវត្តន៍ថ្មីៗនាំស្ថានភាពសេដ្ឋកិច្ចកម្ពុជា រួមទាំងបានបង្ហាញពីផលិតផលក្នុងស្រុកសរុប និងសម្រាប់មនុស្សម្នាក់នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។ ក៏មានបង្ហាញផងដែរពី ការវិនិយោគ ការចំណាយសាធារណៈ និងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជានា១ទសវត្សរ៍ចុងក្រោយនេះ។
- **ជំពូកទី៣ ស្ថានភាពគោលនយោបាយរូបិយវត្ថុនៅកម្ពុជា**៖ នៅជំពូកនេះ នឹងធ្វើការបកស្រាយពីបច្ចុប្បន្នភាពគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងឆ្នាំ២០១៨ និងបង្ហាញពី

ការអនុវត្តគោលនយោបាយនេះ ដោយប្រើឧបករណ៍គោលនយោបាយរូបិយវត្ថុសំខាន់ៗ រួមទាំងឥទ្ធិពលរបស់វាទៅលើការកសាងកំណើនសេដ្ឋកិច្ចកម្ពុជា។

- **ជំពូកទី៤ ការសិក្សាលើការវិភាគ និងបកស្រាយលទ្ធផល៖** នៅជំពូកនេះ នឹងធ្វើការវិភាគ និងបកស្រាយលើទិន្នន័យដែលពាក់ព័ន្ធនឹងការកសាងកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈការអនុវត្តឧបករណ៍គោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជានាពេលកន្លងមក។រួមទាំង ការសិក្សាពីមេគុណនៃអថេរនីមួយៗ និងបកស្រាយលទ្ធផលផងដែរ។
- **សេចក្ដីសន្និដ្ឋាន និងអនុសាសន៍៖** នៅចំណុចនេះជាចំណុចចុងក្រោយនៃការសិក្សា ដែលនឹងធ្វើការសរុបលទ្ធផល និងធ្វើសេចក្ដីសន្និដ្ឋាន រួមទាំងផ្ដល់អនុសាសន៍មួយចំនួនទៅលើចំណុចខ្វះខាត។
- **ឯកសារយោង**
- **ឧបសម្ព័ន្ធ**

# ជំពូកទី១

# រំលឹកទ្រឹស្តី

# ទ្រឹស្តីនយោបាយរូបិយវត្ថុ

## ១.១. និយមន័យ

### ១.១.១. គោលនយោបាយរូបិយវត្ថុ

គោលនយោបាយរូបិយវត្ថុ គឺសំដៅដល់ដំណើរការដែលអាជ្ញាធររូបិយវត្ថុនៅក្នុងប្រទេសមួយ ដែលមានដូចជាធនាគារកណ្តាលនៃប្រទេសនោះ ឬក្រុមប្រឹក្សារូបិយវត្ថុ ប្រើប្រាស់ឧបករណ៍រូបិយវត្ថុ ដើម្បីធ្វើការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ ក្នុងគោលបំណងរក្សាអត្រាអតិផរណា ឬអត្រាការប្រាក់ ក្នុងទិសដៅរក្សាស្ថិរភាពថ្លៃ បង្កើតការងារ និងជំរុញកំណើនសេដ្ឋកិច្ច[5]។

សេដ្ឋវិទូជាច្រើនបានសន្មត់ថា នៅក្នុងរយៈពេលវែង ធាតុចេញ(Output) គឺមាននិន្នាការថេរ ដូចនេះការប្រែប្រួលនៃការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងសេដ្ឋកិច្ចគឺបានត្រឹមតែធ្វើឲ្យកម្រិតថ្លៃមានការប្រែប្រួលប៉ុណ្ណោះ ឬមានន័យថាការផ្គត់ផ្គង់រូបិយវត្ថុជាអ្នកកំណត់កម្រិតថ្លៃនៅក្នុងសេដ្ឋកិច្ច។ ប៉ុន្តែនៅក្នុងរយៈពេលខ្លី ដោយសារតែកម្រិតថ្លៃ និងថ្លៃពលកម្ម គឺមិនមានការកែតម្រូវភ្លាមៗនោះទេ ហេតុដូច្នេះទើប ការផ្គត់ផ្គង់រូបិយវត្ថុអាចមានឥទ្ធិពលទៅលើធាតុចេញ(Output)[6]។ នៅក្នុងប្រព័ន្ធបុរាណនិយម បរិមាណរូបិយវត្ថុកំណត់កម្រិតថ្លៃ ដែលមានឥទ្ធិពលលើចំណូលពិត នោះមានន័យថាបរិមាណរូបិយវត្ថុកំណត់ចំណូលតាមថ្លៃទីផ្សារ។ ក្នុងន័យនេះ គោលនយោបាយរូបិយវត្ថុមានសារៈសំខាន់ណាស់សម្រាប់សេដ្ឋវិទូបុរាណនិយម។ ស្ថិរភាពរូបិយវត្ថុ ជាការកែតម្រូវសម្រាប់ស្ថិរភាពថ្លៃ។ សម្រាប់សេដ្ឋវិទូបុរាណនិយម គោលនយោបាយរូបិយវត្ថុ គឺមានសារៈសំខាន់សម្រាប់តែការរក្សាស្ថិរភាពថ្លៃ និងការជៀសវាងឥទ្ធិពលអាក្រក់នៃអតិផរណា[7]។

### ១.១.២. ឧបករណ៍គោលនយោបាយរូបិយវត្ថុ

ឧបករណ៍គោលនយោបាយរូបិយវត្ថុ គឺជាឧបករណ៍មួយចំនួនដែលធនាគារកណ្តាលប្រើប្រាស់ដើម្បីកែតម្រូវទីផ្សាររូបិយវត្ថុ និងលក្ខខណ្ឌឥណទាន ដើម្បីសម្រេចគោលបំណងរបស់គោលនយោបាយរូបិយវត្ថុ។ ឧបករណ៍គោលនយោបាយរូបិយវត្ថុត្រូវបានគេបែងចែកជា២ប្រភេទ គឺគោលនយោបាយរូបិយវត្ថុដោយផ្ទាល់ និងគោលនយោបាយរូបិយវត្ថុដោយប្រយោល។

[5] គោលនយោបាយរូបិយវត្ថុ, ធនាគារជាតិនៃកម្ពុជា

[6] Koshy Mathai (September 2009) What Is Monetary Policy? Finance & Development (IMF) ទំព័រ៤៦-៤៧

[7] បណ្ឌិត ហង់ ជួនណារ៉ុន(២០០៩) ម៉ាក្រូសេដ្ឋកិច្ច, ទំព័រ១១៧-១១៨

### ១.១.២.១. ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយប្រយោល

ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយប្រយោលមាន៣ប្រភេទ គឺប្រតិបត្តិការទីផ្សារបើកចំហរ ទុនបម្រុងកាតព្វកិច្ច និងកម្ចីរបស់ធនាគារកណ្តាល។

**ក. ទុនបម្រុងកាតព្វកិច្ច**

ទុនបម្រុងកាតព្វកិច្ច ជាបរិមាណប្រាក់បញ្ញើដែលកំណត់ដោយច្បាប់នៃរដ្ឋនីមួយៗ ដែលធនាគារពាណិជ្ជត្រូវរក្សាទុកនៅក្នុងធនាគារកណ្តាល ជាទម្រង់សាច់ប្រាក់ ឬជាបញ្ញើ។ គេប្រើទុនបម្រុងកាតព្វកិច្ចជាមធ្យោបាយ ដើម្បីបង្កើនបរិមាណរូបិយវត្ថុ ឬបន្ថយបរិមាណរូបិយវត្ថុដែលមាននៅក្នុងទីផ្សារ។ កម្រិតទុនបម្រុងកាតព្វកិច្ច មានឥទ្ធិពលលើស្ថានភាពហិរញ្ញវត្ថុ និងទីផ្សាររូបិយវត្ថុ។ ប្រសិនបើ មានការកាត់បន្ថយទុនបម្រុងកាតព្វកិច្ចរបស់ធនាគារពាណិជ្ជ នោះអាចឲ្យធនាគារពាណិជ្ជមានលទ្ធភាពផ្តល់កម្ចីកាន់តែច្រើនថែមទៀតទៅឲ្យអតិថិជន ឬផ្ទុយមកវិញ។ ដូច្នេះ បរិមាណកម្ចីច្រើនជាងមុន នឹងបង្កើតបរិមាណរូបិយវត្ថុច្រើនជាងមុននៅក្នុងសេដ្ឋកិច្ច ដែលត្រូវបានគេជឿជាក់ថានឹងរុញសកម្មភាពសេដ្ឋកិច្ចឲ្យកើនឡើង។

**ខ. កម្ចីអប្បហារ** ( Discount lending )

បញ្ហាកម្ចីអប្បហារ របស់ធនាគារកណ្តាលបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការបន្ធូរបន្ថយសម្ពាធទុនបម្រុងកាតព្វកិច្ច ដែលគ្រឹះស្ថានទទួលប្រាក់បញ្ញើ តែងតែប្រឈមមុខជារៀងរាល់ថ្ងៃ។ នៅក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍប្រព័ន្ធធនាគារ ធនាគារពាណិជ្ជខ្ចីប្រាក់ពីធនាគារកណ្តាលដោយយកមូលបត្រ និងឯកសារទ្រព្យសកម្មផ្សេងៗទៀត ដើម្បីដាក់ធានាបញ្ចាំក្នុងគោលបំណងទទួលបាននូវកម្ចីអប្បហារ។ ជាទូទៅបរិមាណទឹកប្រាក់ដែលត្រូវឲ្យខ្ចីគឺស្មើនឹង តម្លៃចារឹក(Face Value) នៃទ្រព្យសកម្ម ដកនឹងតម្លៃអប្បហារ(Discount)។ លើសពីនេះ ធនាគារពាណិជ្ជ អាចទិញយកមូលបត្រ ឬទ្រព្យសកម្មរបស់ខ្លួនមកវិញ ក្រោយពីបានលក់វាដើម្បីយកប្រាក់បង្វិលរយៈពេលខ្លី តាមយៈកិច្ចព្រមព្រៀងទិញយកមកវិញ។

ដោយឡែក អត្រាអប្បហារ(Discount Rate) គឺជាអត្រាការប្រាក់ដែលធនាគារពាណិជ្ជត្រូវបង់លើកម្ចីដែលខ្លួនបានខ្ចីពីយន្តការកម្ចីអប្បហាររបស់ធនាគារកណ្តាល គឺបញ្ហាអប្បហារ។ ជាទូទៅ អត្រាអប្បហារ មិនមានការប្រែប្រួលញឹកញាប់នោះទេ។ ការប្រែប្រួលនៃអត្រាអប្បហារ នឹងធ្វើឲ្យមានការផ្លាស់ប្តូរលក្ខខ័ណ្ឌឥណទាន។ ជាក់ស្តែង ការបង្កើនអត្រាអប្បហាររបស់ធនាគារកណ្តាល នឹងធ្វើឲ្យស្ថាប័នបញ្ញើត្រូវចំណាយថ្លៃដើមច្រើន លើកម្ចីដែលខ្ចីពីធនាគារកណ្តាល។ ការកើនឡើងនៃថ្លៃដើមសម្រាប់កម្ចីឥណទានពីធនាគារកណ្តាលនឹងរីករាលដាលដល់គ្រប់ប្រភេទអត្រាការប្រាក់ទាំងអស់ក្នុងវិស័យធនាគារ។ ដោយសារតែថ្លៃដើមកម្ចីមានការ

កើនឡើងខ្លាំងបែបនេះ ទើបធ្វើឲ្យធនាគារពាណិជ្ជ ឬស្ថាប័នបញ្ញើ មានការគិតគូរពីការកាត់បន្ថយការផ្តល់កម្ចី និងកម្រិតការផ្តល់កម្ចីទៅឲ្យអ្នកខ្ចីដែលមានហានិភ័យខ្ពស់ ឬការប្រាក់កម្ចីមានការកើនឡើង។

**គ. ប្រតិបត្តិការទីផ្សារបើកចំហរ**

ប្រតិបត្តិការទីផ្សារបើកចំហរ គឺជាឧបករណ៍ដែលអាជ្ញាធររូបិយវត្ថុនៅក្នុងប្រទេសអភិវឌ្ឍន៍ ប្រើច្រើនញឹកញាប់ជាងគេបំផុត ហើយក៏ជាឧបករណ៍គោលនយោបាយរបស់ធនាគារកណ្តាលដែលមានសារៈសំខាន់ និងមានប្រយោជន៍បំផុតនៅក្នុងការគ្រប់គ្រងអត្រាការប្រាក់។ ប្រតិបត្តិការបើកជំហររួមមាន ការទិញដូរឧបករណ៍រូបិយវត្ថុដោយធនាគារកណ្តាលនៅលើទីផ្សារដំបូង ឬទីផ្សារបន្ទាប់។ ឧបករណ៍ទាំងនោះរួមមាន បណ្ណរតនាគារ បណ្ណធនាគារកណ្តាល ឬផលបត្រពាណិជ្ជកម្ម[8] ជាដើម។

នៅពេលដែលធនាគារកណ្តាលទិញមូលបត្ររដ្ឋពីធនាគារពាណិជ្ជ នោះទុនបម្រុងរបស់ធនាគារពាណិជ្ជដែលតំកល់ទុកនៅក្នុងធនាគារកណ្តាលនឹងកើនឡើង ដែលជាហេតុនាំឲ្យធនាគារពាណិជ្ជមានលទ្ធភាពផ្តល់កម្ចីដល់អតិថិជនបានកាន់តែច្រើន។ ដូច្នេះ គេអាចនិយាយបានថា ការទិញមូលបត្ររដ្ឋបង្កើនទុនបម្រុង ហើយបន្ធូរឥណទាន។ ផ្ទុយទៅវិញ ការលក់មូលបត្ររដ្ឋនឹងបន្ថយទុនបម្រុង និងរឹតបន្តឹងឥណទាន។ ប្រតិបត្តិការទីផ្សារចំហរមានឥទ្ធិពលយ៉ាងខ្លាំងលើអត្រាការប្រាក់ តែវាអាស្រ័យទៅលើបរិមាណទិញ និងលក់នូវមូលបត្ររបស់រដ្ឋ។ ការទិញមូលបត្ររបស់ធនាគារកណ្តាល នឹងបង្កើនតម្រូវការមូលបត្រ ជាលទ្ធផលនឹងនាំឲ្យតម្លៃនៃមូលបត្រកើនឡើង ចំណែកឯអត្រាការប្រាក់វិញនឹងធ្លាក់ចុះ។

**១.១.២.២. ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយផ្ទាល់**

ឧបករណ៍ផ្ទាល់ប្រើដើម្បីកំណត់ ឬកម្រិតទាំងអត្រាការប្រាក់ និងបរិមាណកម្ចី ដោយប្រើបទបញ្ញត្តិ។ ឧបករណ៍ផ្ទាល់ដែលប្រើប្រាស់ជាញឹកញាប់គឺ ការគ្រប់គ្រងអត្រាការប្រាក់ ការកំណត់ពិដានឥណទាន និងការកំណត់ទិសដៅប្រាក់កម្ចី។ ជាទូទៅ រដ្ឋាភិបាលចូលច្រើនប្រើវិធីនេះដើម្បីបង្ហូរឥណទានចូលទៅក្នុងទីផ្សារដើម្បីសម្រេចគោលដៅជាក់លាក់ណាមួយ។ ក្នុងប្រទេសដែលមានប្រព័ន្ធហិរញ្ញវត្ថុនៅទន់ខ្សោយ និងគ្មានការប្រកួតប្រជែង នោះការគ្រប់គ្រងផ្ទាល់ជាជម្រើសតែមួយគត់។

[8] ផលបត្រពាណិជ្ជកម្ម(Commercial Paper) គឺជាប្រភេទបណ្ណបំណុលរយៈពេលខ្លីដែលចេញផ្សាយលក់ដោយក្រុមហ៊ុនមានកេរ្តិ៍ឈ្មោះណាមួយ ដើម្បីទទួលបានសាច់ប្រាក់សម្រាប់ធ្វើហិរញ្ញប្បទានលើសន្និធិ និងគណនីអ្នកផ្គត់ផ្គង់។ ជាទូទៅ អាចមានរយៈពេលប៉ុន្មានថ្ងៃ ឬ២ ទៅ៣សប្តាហ៍ ឬក៏៦ខែ ឬយ៉ាងតិច១ឆ្នាំ។

ក៏ប៉ុន្តែការប្រើប្រាស់ឧបករណ៍គោលនយោបាយរូបិយវត្ថុដោយផ្ទាល់ ធ្វើឲ្យមានការបែងចែកធនធានគ្មានប្រសិទ្ធិភាព និងគ្មានសមធម៌ តាមរយៈការកេងបន្លំ ការកំហិតការប្រកួតប្រជែង និងរារាំងមិនឲ្យមានធនាគារថ្មីៗជាដើម។

- ការកំណត់ពិដានឥណទាន (Credit Ceiling) គឺសំដៅដល់ការកម្រិតភាគរយអតិបរមាដែលធនាគារពាណិជ្ជ ទទួលបានការអនុញ្ញាតជាមុន ឲ្យបង្កើនសន្និធិទ្រព្យសកម្មតាមប្រភេទនីមួយៗ នៅក្នុងរយៈពេលណាមួយ។
- ការកំណត់ទិសដៅឥណទាន( Directed Lending) ត្រូវបានអនុវត្តនៅពេលដែលធនធានហិរញ្ញវត្ថុត្រូវបានបែងចែកតាមការបង្គាប់របស់អាជ្ញាធរ ដើម្បីសម្រេចទិសដៅគោលនយោបាយជាជាងតាមគោលការណ៍ពាណិជ្ជកម្ម។ វិស័យធនាគារត្រូវបានណែនាំឲ្យផ្តល់ហិរញ្ញប្បទានដល់វិស័យ សហគ្រាស ឬគម្រោងតាមទិសដៅរបស់រដ្ឋាភិបាល។
- ការត្រួតពិនិត្យអត្រាការប្រាក់( Interest Rate Control) ជាឧបករណ៍គោលនយោបាយរូបិយវត្ថុដែលអាជ្ញាធរត្រួតពិនិត្យថ្លៃនៅក្នុងទីផ្សារមូលដ្ឋានរូបិយវត្ថុដោយមិនត្រួតពិនិត្យលើបរិមាណឡើយ។ ធនាគារកណ្តាលអាចមានឥទ្ធិពលដោយផ្ទាល់ទៅលើអត្រាការប្រាក់មួយចំនួនតូចប៉ុណ្ណោះ ពោលគឺអត្រាដែលធនាគារកណ្តាលផ្តល់មូលនិធិបន្ថែមទៅធនាគារពាណិជ្ជ។

**១.១.៣. ការផ្គត់ផ្គង់រូបិយវត្ថុ** ( Broad Money )

ការផ្គត់ផ្គង់រូបិយវត្ថុ(M2) គឺជាការរួមបញ្ចូលនៃរូបិយវត្ថុដែលកាន់កាប់ដោយសាធារណជន និងប្រាក់បញ្ញើដែលសាធារណជនដាក់ផ្ញើនៅធនាគារពាណិជ្ជ[9]។

ចំពោះការវាស់វែងបរិមាណរូបិយវត្ថុត្រូវបានធ្វើឡើងតាមស្តង់ដារនៃការកំណត់របស់អាជ្ញាធររូបិយវត្ថុនៃប្រទេសនីមួយៗ។ ប៉ុន្តែជាទូទៅ បរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) គឺជាផលបូកនៃរូបិយវត្ថុM1 និងរូបិយវត្ថុផ្សេងៗទៀត។

- រូបិយវត្ថុM1 = រូបិយវត្ថុដែលកំពុងចរាចរណ៍ និងកាន់កាប់ដោយសាធារណជន បូកជាមួយនឹងប្រតិបត្តិការប្រាក់បញ្ញើដែលមាននៅក្នុងគ្រឹះស្ថានទទួលប្រាក់បញ្ញើ (transaction deposits at depository institutions) បូកនឹងមូលប្បទានបត្រផ្សេងៗ (Other Checkable Deposits) ។

[9] រូបិយវត្ថុរួមជាអ្វី? ធនាគារជាតិនៃកម្ពុជា, [https://www.nbc.org.kh/about_the_bank/banking_terms.php] (អានថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០)

- រូបិយវត្ថុទូទៅ[10]M2 = រូបិយវត្ថុM1(រូបិយវត្ថុក្នុងចរាចរណ៍ និងប្រាក់បញ្ញើចរន្តជារៀល) + រូបិយវត្ថុផ្សេងៗ(Quasi Money ដែលរួមមានប្រាក់បញ្ញើមានកាលកំណត់ និងសន្សំជារៀល និងប្រាក់បញ្ញើជារូបិយបណ្ណគ្រប់ប្រភេទរបស់និវាសជន ដែលជាទូទៅអាចបំប្លែងទៅជាសាច់ប្រាក់យឺតជាងរូបិយវត្ថុM1ក្នុងការប្រើប្រាស់សម្រាប់ទូទាត់)។

អស់រយៈកាលដ៏យូរដែល ការផ្គត់ផ្គង់រូបិយវត្ថុត្រូវបានគេសង្កេតឃើញថា មានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងអថេរផ្សេងៗនៅក្នុងសេដ្ឋកិច្ច ដូចជា ផលិតផលក្នុងស្រុកសរុប(GDP) ហើយនឹងកម្រិតថ្លៃជាដើម។ ចំពោះការសន្និដ្ឋាននេះ សេដ្ឋវិទូដ៏ល្បីឈ្មោះ គឺលោក Milton Friedman ធ្លាប់បានធ្វើការពន្យល់ពីឥទ្ធិពលនៃការផ្គត់ផ្គង់រូបិយវត្ថុនៅក្នុងទីផ្សារដែលធ្វើឲ្យមានការកំណត់នូវកម្រិតថ្លៃ និងអតិផរណានៅក្នុងរយៈពេលវែង។ ធនាគារកណ្តាលអាមេរិក ធ្វើការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុ និងកម្រិតថ្លៃដោយប្រយ័ត្នប្រយែងតាមរយៈគោលនយោបាយរូបិយវត្ថុ។

### ១.១.៤. អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់ គឺជាតម្លៃរូបិយវត្ថុរបស់ប្រទេសមួយធៀបនឹងរូបិយបណ្ណរបស់ប្រទេសដទៃទៀត។ អត្រាប្តូរប្រាក់ត្រូវបានគេចែកចេញជាពីរប្រភេទគឺ៖ អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ និងអត្រាប្តូរប្រាក់ពិត។ ជាទូទៅ អត្រាប្តូរប្រាក់តែងតែត្រូវបានបង្ហាញក្នុងទម្រង់នៃតម្លៃរូបិយបណ្ណបរទេស ដែលអាចទិញនូវ១ឯកតានៃរូបិយបណ្ណក្នុងស្រុក[11]។

អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ គឺជាថ្លៃប្រៀបធៀបនៃរូបិយវត្ថុរបស់ប្រទេសពីរ។ ឧទាហរណ៍៖ អត្រាប្តូរប្រាក់ រៀល-ដុល្លារ ស្មើនឹង៤,០០០រៀលក្នុង១ដុល្លារអាមេរិក។

ចំណែកអត្រាប្តូរប្រាក់ពិតវិញ គឺជាថ្លៃប្រៀបធៀបនៃទំនិញនៅក្នុងប្រទេសពីរ។ អត្រាប្តូរប្រាក់ពិតគឺបង្ហាញឲ្យឃើញពីអត្រាដែលយើងអាចដោះដូរទំនិញរបស់ប្រទេសមួយ ជាមួយទំនិញនៃប្រទេសមួយទៀត។

គេអាចគណនាអត្រាប្តូរប្រាក់ពិតតាមរូបមន្ត៖

[10] ធនាគារកណ្តាលសហរដ្ឋអាមេរិក បានកំណត់បរិមាណរូបិយវត្ថុM2 = M1 បូកនឹង ប្រាក់បញ្ញើសន្សំ (Saving deposits) ដែលមានដូចជាប្រាក់បញ្ញើមានការកំណត់ដែលមានតម្លៃចារឹកតូច (small-denomination time deposits, នៅសហរដ្ឋអាមេរិកគេកំណត់ចំនួនតិចជាង១០០,០០០ដុល្លារអាមេរិក), និងសមតុល្យនៃមូលនិធិសង្គហធននៅក្នុងទីផ្សារ (balances in retail money market mutual funds), What is the money supply? Is it important? The Federal Reserve, The central bank of the United states, [https://www.federalreserve.gov/faqs/money_12845.htm] (អានថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០)

[11] Exchange Rates, [https://www.sparknotes.com/economics/macro/trade/section3/] (អានថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០)

$$អត្រាប្តូរប្រាក់ពិត(R) = អត្រាប្តូរប្រាក់តាមថ្លៃទីផ្សារ(E) \times \frac{ថ្លៃទំនិញក្នុងស្រុក(P)}{ថ្លៃទំនិញបរទេស(P^*)}$$

ប្រសិនបើអត្រាប្តូរប្រាក់ពិតទាប នោះទំនិញក្នុងស្រុកនឹងថោក។ អ្នកប្រើប្រាស់នឹងទិញទំនិញនាំចូលកាន់តែតិចទៅៗ។ កត្តានេះនឹងធ្វើឲ្យមានការនាំចេញទំនិញក្នុងស្រុកយកទៅលក់នៅក្រៅប្រទេសកាន់តែច្រើនដោយសារតែតម្លៃនៃទំនិញក្នុងស្រុកថោកជាងទំនិញបរទេស។ ផ្ទុយទៅវិញ ប្រសិនបើអត្រាប្តូរប្រាក់ពិតកាន់តែខ្ពស់ នោះទំនិញដែលផលិតក្នុងស្រុកកាន់តែថ្លៃ។ អ្នកប្រើប្រាស់នឹងសម្រេចចិត្តទិញទំនិញក្នុងស្រុកតិចទៅៗ ហើយការនាំចូលទំនិញបរទេសដែលថោកជាង នឹងមានការកើនឡើង[12]។

### ១.១.៥. ផលិតផលក្នុងស្រុកសរុប(GDP)

ផលិតផលក្នុងស្រុកសរុប ឬGross Domestic Product គឺជាតម្លៃដែលមានទម្រង់ជារូបិយវត្ថុនៃផលបូកតម្លៃទំនិញ ឬសេវាសម្រេច ដែលផលិតបាននៅក្នុងប្រទេសមួយ នៅក្នុងអំឡុងពេលជាក់លាក់ណាមួយ។ គួរបញ្ជាក់ដែរថា ចំនួននេះ គឺរាប់បញ្ចូលទាំងផលិតផល ដែលក្រុមហ៊ុនបរទេសដែល មករកស៊ីនៅក្នុងប្រទេសនោះបានផលិតផងដែរ។ GDP ត្រូវបានគេបែកចែកជាពីរ គឺ Real GDP ដោយគណនាប្រើថ្លៃទំនិញនៅឆ្នាំគោលដែលបានកំណត់។ ចំណែក Nominal GDP ដោយប្រើថ្លៃទីផ្សារបច្ចុប្បន្នមកគណនា។

ជាទូទៅ គេអាចរកចំនួនផលិតផលក្នុងស្រុកនេះបាន តាមរយៈការគណនារកការចំណាយសរុប ដូចជាការចំណាយប្រចាំថ្ងៃរបស់អ្នក ការចំណាយលើការវិនិយោគ ការចំណាយរបស់រដ្ឋាភិបាល និងការនាំចេញសុទ្ធជាដើម។

គេអាចគណនារកផលិតផលក្នុងស្រុកសរុបតាមរូបមន្តៈ

$$GDP = C + I + G + NX$$

ដើម្បីរកកំណើនសេដ្ឋកិច្ចគេអាចគណនាតាមៈ

$$GDP\ Growth\ Rate = \frac{GDP_{(t+1)} - GDP_t}{GDP_t} \times 100$$

[12] បណ្ឌិត ហង់ ជួនណារ៉ុន, ម៉ាក្រូសេដ្ឋកិច្ច(២០០៩), ទំព័រ ១៤៧-១៤៩

គេក៏អាចរកតាមរយៈការបូកបញ្ចូលគ្នានៃតម្លៃបន្ថែមដែលកើតឡើងនៅក្នុងដំណើរការផលិតកម្ម និងដោះដូរ ហើយក៏អាចរកបានតាមផលបូកចំណូលដែលប្រជាពលរដ្ឋរកបាន$(wl + rk)$ ចំណូលរបស់សហគ្រាស និងរួមផ្សំនឹងចំណូលផ្សេងៗទៀតផងដែរ នៅក្នុងប្រទេស។ គេប្រើប្រាស់ GDP ដើម្បីជាទិន្នន័យនៅក្នុងការវិភាគពីស្ថានភាពសេដ្ឋកិច្ចប្រទេសមួយថាតើមានភាពសកម្មប៉ុណ្ណា ហើយក៏ត្រូវបានប្រើដើម្បីព្យាករណ៍ពីទំហំនៃសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំផងដែរ។

## ១.២. ករណីសិក្សាកន្លងមក

បន្ថែមពីការសិក្សាលើទ្រឹស្តី ក៏មានផងដែរបទពិសោធន៍នៃការសិក្សាស្រាវជ្រាវលើករណីជាច្រើន ដែលផ្តោតសំខាន់លើការសិក្សាពីឥទ្ធិពលនៃនយោបាយរូបិយវត្ថុលើកំណើនសេដ្ឋកិច្ច នៅក្នុងបណ្តាប្រទេសជាច្រើនដោយអ្នកសិក្សា។

**ប្រអប់ទី១៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុលើសេដ្ឋកិច្ចកម្ពុជា**

(Mardy Lut & Pahlaj Moolio, 2015) នៅក្នុងប្រទេសកម្ពុជាក៏មានការសិក្សាពីបញ្ហានេះផងដែរ នាពេលកន្លងមក ដោយធ្វើការសិក្សាពីឥទ្ធិពលនៃការផ្គត់ផ្គង់រូបិយវត្ថុ(M2) និងអត្រាការប្រាក់(r) ទៅលើការកសាងកំណើនសេដ្ឋកិច្ច(GDP)កម្ពុជានៅចន្លោះឆ្នាំ២០០០ ដល់២០១២ ដោយប្រើវិធីសាស្ត្រ Multiple Regression Model នៅក្នុងការវិភាគ។ ជាលទ្ធផល ការសិក្សានេះបានបង្ហាញថា ការផ្គត់ផ្គង់រូបិយវត្ថុគឺមានឥទ្ធិពលជាវិជ្ជមានទៅលើកំណើនសេដ្ឋកិច្ច ពោលគឺប្រសិនបើមានការកើនឡើងនូវការផ្គត់ផ្គង់រូបិយវត្ថុ(M2)ចំនួន១ពាន់លានរៀល នឹងធ្វើឲ្យផលិតផលក្នុងស្រុកសរុប(GDP) មានការកើនឡើង0.១៧១៧៣១ពាន់លានរៀល។ ចំណែក ការឡើងចុះនៃអត្រាការប្រាក់នៅកម្ពុជានៅក្នុងចន្លោះឆ្នាំនេះគឺមិនមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ចនោះទេ។ ការសិក្សានេះក៏បានរកឃើញថា ទំនាក់ទំនងរវាងកំណើនសេដ្ឋកិច្ច និងការផ្គត់ផ្គង់រូបិយវត្ថុគឺមានភាពពាក់ព័ន្ធគ្នាក្នុងកម្រិតខ្សោយ ដោយមាន adjusted R-square តែ៥.៧%ប៉ុណ្ណោះ។ អ្នកស្រាវជ្រាវក៏បានផ្តល់ជាគំនិតថា ការសិក្សាលើកក្រោយគួរបន្ថែមនូវអថេរមួយទៀតនោះគឺ អត្រាប្តូរប្រាក់ចូលក្នុងការវិភាគផងដែរ។

**ប្រអប់ទី២៖ ករណីសិក្សាពីឥទ្ធិពលនៃអត្រាប្តូរប្រាក់លើកំណើនសេដ្ឋកិច្ចកម្ពុជា**

(Long Vorlak, Ignatius Abasimi, Yang Fan, ២០១៩) ការសិក្សានេះផ្តោតទៅលើឥទ្ធិពលនៃអត្រាប្តូរប្រាក់នៅកម្ពុជាលើកំណើនសេដ្ឋកិច្ចក្នុងចន្លោះឆ្នាំ១៩៩៥ដល់២០១៧ ដោយយកទិន្នន័យពីធនាគារពិភពលោក។ អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្រ ordinary least squares (OLS) Model សម្រាប់ការវិភាគដែលមានអថេរចូលរួមដូចជា ផលិតផលក្នុងស្រុកសរុប(GDP), អត្រាប្តូរប្រាក់(EXR), ការបើកទូលាយពាណិជ្ជកម្ម(TOP), អត្រាអតិផរណា(IFR), ការវិនិយោគផ្ទាល់ពីបរទេស(FDI) និងបរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2)។ ជាលទ្ធផល មានតែអត្រាប្តូរប្រាក់ និងការបើកចំហរពាណិជ្ជកម្មទេដែលមានឥទ្ធិពលសំខាន់ជាងគេលើកំណើនសេដ្ឋកិច្ច(GDP) កម្ពុជា ក្នុងហានិភ័យ១%។ អត្រាប្តូរប្រាក់មានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច ដែលមានន័យថា ប្រសិនបើអត្រាប្តូរប្រាក់មានការកើនឡើង១ឯកតា នោះកំណើនសេដ្ឋកិច្ចនឹងកើនឡើង៣.៣៣ឯកតា។ ចំណែក ការបើកចំហរពាណិជ្ជកម្មវិញ មានទំនាក់ទំនងអវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច មានន័យថា ប្រសិនបើ TOP មានការធ្លាក់ចុះ១ឯកតា នោះសេដ្ឋកិច្ចនឹងកើនឡើង២.១៧ឯកតា។

**ប្រអប់ទី៣៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុក្នុងប្រទេសស៊ីរីលង្កា**

(Sugathadasa, 2018) នៅប្រទេសស៊ីរីលង្កា ក៏មានការសិក្សាទៅលើឥទ្ធិពល និងភាពសំខាន់នៃនយោបាយរូបិយវត្ថុនៅក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចដែរ។ អ្នកស្រាវជ្រាវ បានធ្វើការអង្កេតទៅលើទិន្នន័យរយៈពេល៣៣ឆ្នាំ ពោលគឺចាប់ពីឆ្នាំ១៩៨៥ ដល់២០១៧ ដើម្បីពិនិត្យមើលឥទ្ធិពលនៃឧបករណ៍នយោបាយរូបិយវត្ថុ ដូចជាអត្រាការប្រាក់ (r) អត្រាប្តូរប្រាក់(EX) និងការផ្គត់ផ្គង់រូបិយវត្ថុ(M2) នៅក្នុងការកសាងកំណើនសេដ្ឋកិច្ច(GDP) ដោយប្រើវិធីសាស្ត្រ Multiple Regression Analysis និងCorrelation នៅក្នុងកម្មវិធី SPSS។ ជាលទ្ធផលបង្ហាញថា អត្រាការប្រាក់(r) និងអត្រាប្តូរប្រាក់(EX) មិនមានទំនាក់ទំនងជាsignificant ជាមួយនឹងកំណើនសេដ្ឋកិច្ច(GDP)ប្រទេសស៊ីរីលង្ការនោះទេ។ ផ្ទុយទៅវិញ ការផ្គត់ផ្គង់រូបិយវត្ថុគឺមានទំនាក់ទំនងជាវិជ្ជមាន ជាមួយនឹងកំណើនសេដ្ឋកិច្ច ហើយក៏ជាកត្តាតែមួយគត់ដែលអ្នកសិក្សាសន្និដ្ឋានថាមានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចប្រទេសស៊ីរីលង្ការក្នុងរយៈពេល៣៣ឆ្នាំចុងក្រោយនេះ។

**ប្រអប់ទី៤៖ ករណីសិក្សាពីឥទ្ធិពលនៃគោលនយោបាយរូបិយវត្ថុនៅប្រទេសប៉ាគីស្ថាន**

(Sidra Ayub & Faiza Maqbool Shah, 2015) នៅក្នុងប្រទេស ប៉ាគីស្ថាន ក៏មានការសិក្សាផងដែរអំពីបញ្ហានេះ ដោយធ្វើការសិក្សារយៈពេល១០ឆ្នាំ ពោលគឺនៅចន្លោះឆ្នាំ២០០៥ ដល់២០១៤ ដោយសិក្សាពីឥទ្ធិពលនៃការផ្គត់ផ្គង់រូបិយវត្ថុ(M2) អតិផរណា(Inflation) និងអត្រាការប្រាក់(r) លើកំណើនសេដ្ឋកិច្ច(GDP) ប្រទេសប៉ាគីស្ថាន។ នៅក្នុងការវិភាគនេះ វិធីសាស្ត្រ Regression Analysis នៅក្នុងកម្មវិធី SPSS ត្រូវបានប្រើ។ ជាលទ្ធផលបង្ហាញថា ការផ្គត់ផ្គង់រូបិយវត្ថុ(M2) មានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច ពោលប្រសិនបើ១%កើននៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុ នោះកំណើនសេដ្ឋកិច្ចនឹងកើន0.៤៨%។ ចំពោះអត្រាការប្រាក់វិញ គឺមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច។ ប្រសិនបើអត្រាការប្រាក់មានការធ្លាក់ចុះ១% នោះកំណើនសេដ្ឋកិច្ចនឹងកើនឡើង0.៤៤៦%។ ចំណែកឯ អត្រាអតិផរណាវិញ គឺមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច ពោលប្រសិនបើអត្រាអតិផរណាមានការធ្លាក់ចុះ១% នោះកំណើនសេដ្ឋកិច្ចនឹងកើនឡើង0.៤៤៦%។ (Hameed, Irfan & Ume, Amen, 2015) ក៏មានផងដែរ ការសិក្សានៅក្នុងប្រទេសប៉ាគីស្ថានដដែល ដោយធ្វើការសិក្សារយៈពេល៣0ឆ្នាំ ពោលគឺនៅឆ្នាំ១៩៨០ ដល់២០០៩ ដោយសិក្សាលើឥទ្ធិពលនៃអត្រាការប្រាក់(r) និងការផ្គត់ផ្គង់រូបិយវត្ថុ(M2) លើកំណើនសេដ្ឋកិច្ច(GDP) ប្រទេសប៉ាគីស្ថាន។ នៅក្នុងការវិភាគនេះអ្នកសិក្សាបានប្រើវិធីសាស្ត្រ Regression Analysis នៅក្នុងកម្មវិធី SPSS។ ជាលទ្ធផលបង្ហាញថា Model ត្រូវបានពន្យល់រហូតដល់ទៅ៨១.១% ហើយការផ្គត់ផ្គង់រូបិយវត្ថុ(M2) មានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច ពោលប្រសិនបើ១ឯកតាកើននៅក្នុងការផ្គត់ផ្គង់រូបិយវត្ថុ នោះកំណើនសេដ្ឋកិច្ចនឹងកើនរហូតដល់១៥៥៦៣៩.៦ឯកតា។ ចំពោះ អត្រាការប្រាក់វិញ គឺមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច។ ប្រសិនបើអត្រាការប្រាក់មានការធ្លាក់ចុះ១ឯកតា នោះកំណើនសេដ្ឋកិច្ចនឹងកើនឡើង៣១៨៧២០៩ឯកតា។

# ជំពូកទី២

# ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

# ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

## ២.១. ការវិវត្តន៍ថ្មីៗនៃស្ថានភាពសេដ្ឋកិច្ចកម្ពុជា

នៅក្នុងរបាយការណ៍បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០១៩របស់ធនាគារពិភពលោក[13] ដែលបង្ហាញថាកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ៧,៥ភាគរយនៅក្នុងឆ្នាំ២០១៨ ដែលជាអត្រាកំណើនល្អជាងការរំពឹងទុកទៅទៀត បើធៀបនឹងអត្រាកំណើន៧%នៅក្នុងឆ្នាំ២០១៧។ ដោយមានការជំរុញមួយផ្នែកធំពីការកើនយ៉ាងរហ័សនៃការនាំចេញ និងការបន្តលូតលាស់នៃវិស័យសំណង់ បូករួមទាំងតម្រូវការក្នុងស្រុកមានកម្រិតខ្ពស់ជាងមុន។ ការនាំចេញកើនឡើងយ៉ាងឆាប់រហ័សដោយសារតែតម្រូវការខាងក្រៅ ជាពិសេសការនាំចេញទៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប មានភាពរឹងមាំ។ ដោយឡែកការនាំចេញសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួនពីរភាគបីនៃការនាំចេញទំនិញសរុបកើនឡើងពី៨.៣%នៅក្នុងឆ្នាំ២០១៧ ដល់ ១៧.៦%នៅក្នុងឆ្នាំ២០១៨។ ទំនុកចិត្តអ្នកប្រើប្រាស់ទំនិញមានការកើនឡើង ដែលធ្វើឲ្យមានកំណើននៃការនាំចូល ជាពិសេសការនាំចូលរថយន្តដែលមានការកើនឡើងនៅក្នុងអត្រា៥០% និង៤៨%សម្រាប់ការនាំចូលដែកសំណង់។ វិស័យសំណង់ អចលនទ្រព្យ និងទេសចរណ៍ សរុបគ្នាមក មានចំណែក៦០ភាគរយ នៃចំនួនគម្រោងវិនិយោគទាំងអស់ដែលត្រូវបានអនុម័តរួចក្នុងឆ្នាំ២០១៨។ ការផលិតសម្ភារផ្គត់ផ្គង់ការសាងសង់ ដែកគ្រឿងសង្ហារឹម និងផលិតផលប្លាស្ទិចក៏មានការកើនឡើងយ៉ាងលឿនដែរ ដើម្បីគាំទ្រដល់ការលូតលាស់របស់វិស័យសំណង់។

ចំណែកឯ អតិផរណាវិញ បានថយចុះបន្តិច ដោយសារតែការជួយមួយផ្នែកនៃការរក្សាស្ថិរភាពនៃអត្រាប្តូរប្រាក់។ ជាលទ្ធផល អតិផរណា បានថយចុះមកត្រឹម១.៦% គិតត្រឹមខែធ្នូ ឆ្នាំ២០១៨ ចុះពី២.២% នៅក្នុងឆ្នាំ២០១៧។ ប្រាក់រៀលដែលធៀបនឹងប្រាក់ដុល្លាអាមេរិក នៅតែមានតម្លៃថេរក្នុងអត្រា៤០១៨រៀលក្នុង១ដុល្លារអាមេរិកនៅបំណាច់ឆ្នាំ២០១៨ ធៀបនឹងអត្រា៤០៣៧រៀលក្នុង១ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៧។

កិច្ចប្រឹងប្រែងដោយអាជ្ញាធរដើម្បីទាក់ទាញអ្នកទេសចរចិនទទួលបានជោគជ័យ។ ការមកដល់របស់អ្នកទេសចរបានកើនឡើងដល់ ៣លាននាក់ ក្នុងកំឡុងឆមាសទីមួយឆ្នាំ ២០១៨ និងអ្នកទេសចរចិនបានឈរក្នុងចំណាត់ថ្នាក់លេខមួយ (បន្ទាប់មក មានភ្ញៀវជនជាតិវៀតណាម ឡាវ និងសាធារណរដ្ឋកូរ៉េ) ក៏ប៉ុន្តែ ស្ថាន

[13] បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៩ ដោយធនាគារពិភពលោក។ [https://www.worldbank.org/km/news/press-release/2019/05/06/world-bank-cambodias-economy-achieves-robust-growth-in-2018] (អានថ្ងៃទី៣ ខែមេសា ឆ្នាំ ២០២០)

ភាពខាងក្រៅរបស់កម្ពុជា នៅតែមានស្ថេរភាព នៅពេលដែលការនាំចេញដែលមានភាពល្អប្រសើរជួយរក្សាតុល្យភាពបានមួយផ្នែកលើកំណើនដ៏ឆាប់រហ័សនៃបរិមាណតម្រូវការនាំចូល និងឱនភាពគណនីចរន្តត្រូវបានគេរំពឹងថានឹងកើនឡើងបន្តិចបន្តួច ក៏ប៉ុន្តែ នៅតែទទួលបានការគាំទ្រផ្នែកហិរញ្ញប្បទានពេញលេញតាមរយៈលំហូរចូលនៃវិនិយោគទុនផ្ទាល់ពីបរទេស[14]។

ប៉ុន្តែ ភាពមិនប្រាកដប្រជាដែលបន្តមានបានបង្កហានិភ័យខ្លាំងឡើងដែរ។ បច្ចុប្បន្ននេះ ទីផ្សារសហភាពអឺរ៉ុប (រួមទាំងចក្រភពអង់គ្លេសផង) ស្រូបយកជាងមួយភាគបីនៃទំហំនៃការនាំចេញសរុបរបស់កម្ពុជា ជាពិសេសផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទោចក្រយាន។ លទ្ធភាពដែលកម្ពុជានឹងអាចបាត់បង់ភាពអនុគ្រោះនាំទំនិញចូលទីផ្សារអឺរ៉ុបដោយរួចពន្ធក្រោមប្រព័ន្ធអនុគ្រោះ «គ្រប់មុខទំនិញទាំងអស់លើកលែងគ្រឿងសព្វាវុធ» (EBA) ទំនងជានឹងអាចបន្ថយល្បឿននៃការនាំចេញពីកម្ពុជា។ បន្ថែមលើនេះ វិស័យសំណង់និងអចលនទ្រព្យកាន់តែងាយធ្លាក់ក្នុងវដ្តស្ថានភាពឆាប់ប៉ោងហើយឆាប់ផ្ទុះបែកទៅវិញ ហើយកំណើនការផ្តល់ហិរញ្ញប្បទានក្នុងស្រុកនៅក្នុងវិស័យសំណង់នឹងកាន់តែបង្កើនហានិភ័យថែមទៀតដល់វិស័យហិរញ្ញវត្ថុដែរ។

**២.១.១. ផលិតផលក្នុងស្រុកសរុប**(GDP)

ផលិតផលក្នុងស្រុកសរុបពិត(GDP) របស់ប្រទេសកម្ពុជា មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ និន្នាការនៃការកើនឡើងនេះបានបង្ហាញពីការរីកចម្រើន និងភាពរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា។ ជាក់ស្តែងនៅក្នុងឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបពិតរបស់កម្ពុជា មានចំនួន ១០,៦០៩.៦១៥ លានដុល្លារអាមេរិក ដែលកើនដល់ ១៩,៥៨១.៦៧២ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨។

មូលហេតុនៃការកើនឡើងនេះ ត្រូវបានគេសង្កេតឃើញបានមកពីវិស័យ៤ធំៗ ដែលមានដូចជា វិស័យឧស្សាហកម្មបានដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការរួមចំណែកសាងកំណើនសេដ្ឋកិច្ចកម្ពុជាដែលមានការកើនឡើងគួរឲ្យកត់សម្គាល់ ពោលគឺ២២.៩%នៃផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងឆ្នាំ២០១២ កើនដល់២៦.២%នៃផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងឆ្នាំ២០១៥។ ខណៈដែលវិស័យកសិកម្មមានការធ្លាក់ចុះពី៣៣.៥%នៃផលិតផលក្នុងស្រុកសរុប(GDP)នៅក្នុងឆ្នាំ២០១២ មកត្រឹម២៩%នៅក្នុងឆ្នាំ២០១៥។ ចំពោះវិស័យសំណង់វិញ ក៏មានការកើនឡើងគួរឲ្យកត់សម្គាល់ដែរ ពោលគឺពី៦.៥%នៅក្នុងឆ្នាំ២០១២ ទៅ៨.៨%នៅ

[14] បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៨ ដោយធនាគារពិភពលោក។ (WB)[https://www.worldbank.org/km/country/cambodia/publication/cambodia-economic-update-october-2018-recent-economic-developments-and-outlook] (អានថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០)

ក្នុងឆ្នាំ២០១៥ និងនៅតែរក្សាកំណើនកើនឡើងជារៀងរាល់ឆ្នាំ។ ចំណែកឯ វិស័យសេវាកម្មវិញ បានរួមចំណែកក្នុងការកសាងកំណើនGDPចំនួន៣៩.៤%ឯណោះនៅក្នុងឆ្នាំ២០១៥[15]។

**ក្រាហ្វទី១៖ បង្ហាញពីការវិនិយោគនៃការកើនឡើងនៃផលិតផលក្នុងស្រុកសរុបពិតរបស់កម្ពុជា (២០០៩ដល់២០១៨)**




*ប្រភព៖ ធនាគារពិភពលោក[https://data.worldbank.org]*

*សម្គាល់៖ យកដុល្លារអាមេរិកឆ្នាំ២០១០ជាគោល*

### ២.១.១.១. ផលិតផលក្នុងស្រុកក្នុងប្រជាជនម្នាក់ៗ (GDP Per Capita)

ស្របពេលដែលកំណើនសេដ្ឋកិច្ចកម្ពុជាមានការរីកលូតលាស់យ៉ាងឆាប់រហ័សនា២ទសវត្សន៍ចុងក្រោយនេះ គេក៏សង្កេតឃើញពីនិន្នាការនៃការកើនឡើងផងដែរ នៃចំណូលរបស់ប្រជាពលរដ្ឋខ្មែរម្នាក់ៗអាចរកបាននៅក្នុងមួយឆ្នាំៗ។ តាមការអង្កេតរបស់ធនាគារពិភពលោក(World Bank) បានបង្ហាញថា នៅក្នុងឆ្នាំ២០០៩ ផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនម្នាក់ៗ មានចំនួនតែ ៧៥២.៧៨៦ ដុល្លារអាមេរិក។ ចំនួននេះមានការកើនឡើងដល់ ១,២០៥.០៤១ ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨ ដែលជាតួលេខមួយស្របទៅនឹងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា របស់រដ្ឋាភិបាលកម្ពុជានឹងធ្វើការកែប្រែប្រទេសកម្ពុជាដែលមានចំណូល

[15] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC), កំណើនតាមវិស័យ [http://www.cambodiainvestment.gov.kh/why-invest-in-cambodia/investment-enviroment/economic-trend.html],អានថ្ងៃទី១៧ខែមេសាឆ្នាំ២០២០។

មធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៥០។

**ក្រាហ្វទី២៖ បង្ហាញពីការកើនឡើងនៃផលិតផលក្នុងស្រុកសរុបរបស់ប្រជាជនម្នាក់ៗ**( GDP Per Capita )**នៅកម្ពុជា**( **២០០៩ដល់២០១៨** )




*ប្រភព៖ ធនាគារពិភពលោក[https://data.worldbank.org]*

*សម្គាល់៖ យកដុល្លារអាមេរិកឆ្នាំ២០១០ជាគោល*

## ២.១.២. ពាណិជ្ជកម្មអន្តរជាតិ

ក្រសួងពាណិជ្ជកម្មកម្ពុជា នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨នេះ បានបង្ហាញនូវរបាយការណ៍នៃការនាំចេញ-នាំចូលរបស់កម្ពុជា ដោយបញ្ជាក់ថា នៅឆ្នាំ២០១៨ ទំហំពាណិជ្ជកម្មកម្ពុជា ជាមួយបរទេសសរុបចំនួន ២៤,៩៨៥លានដុល្លារអាមេរិក។ សម្រាប់ការនាំចេញទំនិញ របស់កម្ពុជាទៅតាមបណ្តាប្រទេសផ្សេងៗ គិតជាទឹកប្រាក់១១,២១៥លានដុល្លារអាមេរិក តួលេខនៃការនាំចេញនេះមានការកើនឡើង បើធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៧ មានត្រឹមតែ១០,៧៧៧លានដុល្លារអាមេរិក។ ដោយឡែក សម្រាប់ការនាំចូលរបស់កម្ពុជាវិញ ក៏មានចំនួនច្រើនផងដែរ ដោយមានចំនួន១៣,៧៧១លានដុល្លារអាមេរិក កើនឡើងជាងឆ្នាំ២០១៧ ដែលមានត្រឹមតែ១៣,០១៩លានដុល្លារអាមេរិក។

**ក្រាហ្វទី៣៖ បង្ហាញពីទំហំពាណិជ្ជកម្ម និងការនាំចេញ-ចូលរបស់កម្ពុជាពីឆ្នាំ២០០៩ ដល់២០១៨**




*ប្រភព៖ អគ្គនាយកដ្ឋានកាំកុងត្រូលកម្ពុជា/ ក្រសួងពាណិជ្ជកម្ម*

### ២.១.២.១. ការនាំចូល

(ធនាគារពិភពលោក, បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០១៩) ការកើនឡើងយ៉ាងឆាប់រហ័សនៃតម្រូវការក្នុងស្រុកធ្វើឲ្យមានកំណើននៃការនាំចូលកាន់តែច្រើន។ ការនាំចូលយានយន្តមានការកើនឡើង ៥២.៩% នៅក្នុងឆ្នាំ២០១៨ បន្ទាប់មកប្រេងឥន្ធនៈ គឺជាផលិតផលនាំចូលច្រើនជាងគេលំដាប់ទីពីរ ដែលមានការកើនឡើង៣០% ដែលក្នុងនោះមានប្រេងសាំង និងម៉ាស៊ូត។ ចំណែកឯ វិស័យសំណង់ ក៏មានការនាំចូលច្រើនផងដែរ ដូចជាការនាំចូលដែកថែបដែលបានកើនឡើង៤៧.៦% ម៉ាស៊ីនត្រជាក់ ដែលបានកើនឡើង៥៤.៣% និងសម្ភារសំណង់ផ្សេងៗ ដែលបានកើនឡើង៧៣%។

នៅក្នុងឆ្នាំ២០០៩ ទំហំនៃការនាំចូលរបស់កម្ពុជាមានទំហំ ៣,៧៤០ លានដុល្លារអាមេរិក ដែលកើនដល់១៣,៧៧១ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨។

**ក្រាហ្វទី៤៖ បង្ហាញពីការទំហំនៃការនាំចូលរបស់កម្ពុជានៅចន្លោះឆ្នាំ២០០៩ដល់២០១៨**




*ប្រភព៖ អគ្គនាយកដ្ឋានកាំកុងត្រូលកម្ពុជា/ ក្រសួងពាណិជ្ជកម្ម*

### ២.១.២.២. ការនាំចេញ

**ក្រាហ្វទី៥៖ បង្ហាញពីការទំហំនៃការនាំចេញរបស់កម្ពុជានៅចន្លោះឆ្នាំ២០០៩ដល់២០១៨**




*ប្រភព៖ អគ្គនាយកដ្ឋានកាំកុងត្រូលកម្ពុជា/ ក្រសួងពាណិជ្ជកម្ម*

យោងតាមរបាយការណ៍ បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ដែលចុះផ្សាយដោយ ធនាគារពិភពលោក កាលពីខែឧសភា ឆ្នាំ២០១៩ បានលើកឡើងថា ការនាំចេញកើនឡើងយ៉ាងឆាប់រហ័សដោយសារតែតម្រូវការ

ខាងក្រៅ ជាពិសេសការនាំចេញទៅទីផ្សារសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប មានភាពរឹងមាំ។ ដោយឡែក ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងដែលមានចំនួនពីរភាគបីនៃការនាំចេញទំនិញសរុបកើនឡើងពី ៨.៣%នៅក្នុងឆ្នាំ២០១៧ ដល់១៧.៦%នៅក្នុងឆ្នាំ២០១៨។

ការនាំចេញរបស់កម្ពុជាទៅកាន់សហរដ្ឋអាមេរិក មានការកើនឡើង២៩% នៅក្នុងឆ្នាំ២០១៨ ពោលគឺកើនពី៤.៦%នៅឆ្នាំ២០១៧។ ការនាំចេញរបស់កម្ពុជាទៅកាន់សហភាពអឺរ៉ុបបានកើនឡើង១២.៩%នៅក្នុងឆ្នាំ២០១៨ ពោលគឺកើនឡើងពី៩.៣%នៅក្នុងឆ្នាំ២០១៧។ ចំណែកឯ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងរបស់កម្ពុជាទៅទីផ្សារសហរដ្ឋអាមេរិកកើនដល់២៩.៧% នៅក្នុងឆ្នាំ២០១៨ ដែលកើនពី២៥%នៅក្នុងឆ្នាំ២០១៧។ ចំណែកឯ ការនាំចេញផលិតផលនេះ ទៅកាន់សហភាពអឺរ៉ុបវិញមានការថយចុះមកត្រឹម ៣៩.១% នៅក្នុងឆ្នាំ២០១៨ ពោលគឺថយពីចំណែក៤៦%នៅក្នុងឆ្នាំ២០១៧។

**ប្រអប់ទី៥៖ ទំហំពាណិជ្ជកម្មរបស់កម្ពុជា នៅឆ្នាំ២០១៨ មានទឹកប្រាក់ជិត២៥ពាន់លានដុល្លារ, ការនាំចេញជាង១១ពាន់លានដុល្លារ និងនាំចូលវិញជាង១៣ពាន់លានដុល្លារ**

[...]ថ្លែងក្នុងពិធីបើកសន្និបាតបូកសរុបការងារពាណិជ្ជកម្មឆ្នាំ២០១៨ និងទិសដៅអនុវត្តន៍ការងារពាណិជ្ជកម្មឆ្នាំ២០១៩ ដែលរៀបចំឡើងនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៨នេះ លោក ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានលើកឡើងថា «ក្នុងឆ្នាំ២០១៨នេះការនាំចេញរបស់កម្ពុជា មានការកើនឡើងចំនួន១០% កំណើននេះទទួលបានពី ការកើនឡើងនៃវិស័យកាត់ដេរ និងការនាំចេញផលិតផលកសិកម្ម និងឧស្សាហកម្ម តាមរយៈការខិតខំបើកច្រកទីផ្សារ នាំចេញទៅកាន់ជាង១៤៧ប្រទេសនៅទូទាំងពិភពលោក»។ លោកបន្តថា ការនាំចេញនេះមានទំហំប្រមាណជា ៦០% នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជា សមិទ្ធិផលទាំងអស់នេះបានបង្ហាញថា ក្រសួងពាណិជ្ជកម្មបានចូលរួមចំណែក យ៉ាងសកម្មក្នុងការរក្សា និងពង្រីកកំណើនសេដ្ឋកិច្ចជាតិ ដែលតាមការប៉ាន់ស្មាន គឺមានអត្រាប្រមាណ៧,៣% ក្នុងឆ្នាំ២០១៨នេះ។[...]

*ប្រភព៖ សារព័ត៌មាន Freshnews*

*[http://freshnewsasia.com/index.php/en/localnews/108144-2018-12-24-07-51-41.html]*

### ២.១.៣. ការវិនិយោគ

**តារាងទី១៖ បង្ហាញពីទំហំវិនិយោគក្នុងស្រុក និងផ្ទាល់ពីបរទេស**

| ឆ្នាំ | 2017 | | 2018 | | 2019 | |
|---|---|---|---|---|---|---|
| សរុប | 6.3ពាន់លានដុល្លារអាមេរិក | | 6.4ពាន់លានដុល្លារអាមេរិក | | 9.4ពាន់លានដុល្លារអាមេរិក | |
| ចំណាត់ថ្នាក់ | ប្រទេស | ភាគរយ | ប្រទេស | ភាគរយ | ប្រទេស | ភាគរយ |
| 1 | កម្ពុជា | 50.68 | ចិន | 51.06 | កម្ពុជា | 49.44 |
| 2 | ចិន | 25.97 | កម្ពុជា | 31.15 | ចិន | 39.55 |
| 3 | វៀតណាម | 9.20 | ជប៉ុន | 13.69 | BVI | 4.93 |
| 4 | ម៉ាឡេស៊ី | 4.37 | ថៃ | 0.80 | ជប៉ុន | 3.18 |
| 5 | សាំងហ្គាពួរ | 4.12 | BVI* | 0.76 | ថៃ | 0.78 |
| 6 | កូរ៉េ | 3.20 | ម៉ាឡេស៊ី | 0.68 | វៀតណាម | 0.70 |
| 7 | ជប៉ុន | 1.00 | Samao | 0.67 | សាំងហ្គាពួរ | 0.32 |
| 8 | អង់គ្លេស | 0.88 | សាំងហ្គាពួរ | 0.28 | អង់គ្លេស | 0.28 |
| 9 | ថៃ | 0.25 | អង់គ្លេស | 0.23 | កូរ៉េ | 0.22 |
| 10 | Virgin Islands | 0.12 | កូរ៉េ | 0.23 | ហូឡង់ | 0.15 |
| 11 | ផ្សេងៗ | 0.21 | ផ្សេងៗ | 0.45 | ផ្សេងៗ | 0.45 |

*BVI (British Virgin Islands)

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC)*

ការវិនិយោគនៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនគួរឲ្យគត់សម្គាល់តាំងពីឆ្នាំ២០១២មក ពោលគឺមានការកើនឡើង២៤%គិតចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ បើគិតជាទឹកប្រាក់មានការកើនឡើងពី២.៩ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១២ កើនដល់៣.៦ពាន់លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៦ និងបន្តកើនឡើង៧៥%ទៀតនៅក្នុងឆ្នាំ២០១៧។ នៅក្នុងឆ្នាំ២០១៨ ការវិនិយោគសរុបមានការកើនឡើងចំនួនប្រហែល ២%ពីឆ្នាំ២០១៧ និងមានការកើនឡើងរហូតដល់៤៥%នៅក្នុងឆ្នាំ២០១៩ បើធៀបនឹងឆ្នាំ២០១៨។ បើគិតរយៈពេល៥ឆ្នាំចុងក្រោយមកនេះ ការវិនិយោគមូលធនសរុបនៃវិនិយោគិនក្នុងស្រុកមានប្រមាណជា៣៥%នៃការវិនិយោគសរុប។

ការវិនិយោគសំខាន់ជាងគេគឺស្ថិតនៅក្នុងវិស័យឧស្សាហកម្ម និងហេដ្ឋារចនាសម្ព័ន្ធ ដែលមានចំនួន ៥៣%នៃការវិនិយោគសរុប និងតាមពីក្រោយដោយការវិនិយោគនៅក្នុងវិស័យទេសចរណ៍ដែលមានចំនួន ៤១% និងកសិកម្មមាន៦% នៃការវិនិយោគសរុប។

គម្រោងជាច្រើនត្រូវបានអនុម័តយល់ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) គិតចាប់តាំងពីឆ្នាំ ១៩៩៥មក។ នៅឆ្នាំ១៩៩៥ ពោលគឺ១ឆ្នាំបន្ទាប់ពីមានការដាក់ឲ្យប្រើប្រាស់ច្បាប់ស្តីពីការវិនិយោគនៅកម្ពុជា មានគម្រោងវិនិយោគដែលយល់ព្រមដោយCDCគិតជាទឹកប្រាក់សរុបប្រមាណជា ២.៣ពាន់លានដុល្លារអាមេរិក ហើយទំហំនៃការវិនិយោគនេះមានការកើនឡើងជាបន្តបន្ទាប់ដោយគិតត្រឹមឆ្នាំ២០១៩មានទឹកប្រាក់មានទឹកប្រាក់សរុបប្រមាណជា ៨៥.៨៨ពាន់លានដុល្លារអាមេរិក។ នៅក្នុងឆ្នាំ ២០០៨ ការវិនិយោគមានការកើនឡើងរហូតដល់ទៅ១០.៨៩ពាន់លានដុល្លារអាមេរិក ដែលក្នុងនោះការវិនិយោគក្នុងវិស័យកសិកម្មមានរហូតដល់ទៅ ១០៦.៧៣លានដុល្លារអាមេរិក ខណៈដែលការវិនិយោគនៅក្នុងវិស័យទេសចរណ៍ និងសេវាកម្ម មានចំនួន៨.៧៧ពាន់លានដុល្លារអាមេរិក និង១.២៩ពាន់លានដុល្លារអាមេរិកទៀតនៅក្នុងវិស័យផ្សេងៗ។ ដោយឡែក នៅក្នុងឆ្នាំ២០១៩ ការវិនិយោគដែលបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) មានទំហំទឹកប្រាក់ចំនួន៩.៤០ពាន់លានដុល្លារអាមេរិក ដែលក្នុងនោះវិនិយោគចិនមានច្រើនជាងគេជាមួយនឹងទឹកប្រាក់ចំនួន២.៧៥ពាន់លានដុល្លារអាមេរិក ដែលតាមពីក្រោយដោយហុងកុងចំនួន៩១២.៥៥លានដុល្លារអាមេរិក និងជប៉ុនចំនួន ២៩៨.៨៤លានដុល្លារអាមេរិក។

ចំណែកឯ ការវិនិយោគផ្ទាល់ពីបរទេស(FDI) គិតចាប់តាំងពីឆ្នាំ១៩៩៤ ដល់ឆ្នាំ ២០១៩ ប្រទេសចិនមានចំណែកធំជាងគេដែលមានរហូតដល់ទៅ២១.៨១% ដែលបានធ្វើការវិនិយោគនៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ កៅស៊ូ និងទេសចរណ៍។ សាធារណរដ្ឋកូរ៉េ មានចំនួន៦.១៦% និងចក្រភពអង់គ្លេសមានចំនួន៥.០១%។ ក្រៅពីនេះមានដូចជា ម៉ាឡេស៊ី(៣.៥៩%) ជប៉ុន(៣.១៣%) ហុងកុង(៣.០៥%) តៃវ៉ាន់(១.៧៧%) វៀតណាម (២.៣១%) សឹង្ហបុរី(១.៦៤%) ថៃ(១.៥៤%) ដែលភាគច្រើនគឺវិនិយោគនៅក្នុងឧស្សាហកម្មកាត់ដេរ[16]។

### ២.១.៤. ការចំណាយសាធារណៈ

ចំណាយសរុបថវិការដ្ឋ ឬចំណាយសរុបថវិកាជាតិសម្រាប់ឆ្នាំ២០១៩ ត្រូវបានគ្រោងចំនួន ២៧,១៦៤,៩៩៦ លានរៀល ត្រូវជា ២៤.៧២% នៃផលិតផលក្នុងស្រុកសរុប គឺមានកំណើនចំនួន១១.៤% ធៀបនឹងច្បាប់ឆ្នាំ២០១៨ ដែលក្នុងនោះ (១)ចំណាយចរន្តថវិការដ្ឋមានចំនួន ១៧,៩០៧,៥៤៩ លានរៀល ត្រូវ

[16] ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC), បរិយាកាសវិនិយោគនៅកម្ពុជា,[http://www.cambodiainvestment.gov.kh/why-invest-in-cambodia/investment-enviroment.html]

ជា១៦.៣០% នៃផលិតផលក្នុងស្រុកសរុប គឺមានកំណើន១២.៣% ធៀបនឹងច្បាប់ឆ្នាំ២០១៨ និង (២) ចំណាយមូលធនថវិការជ្ជមានចំនួន ៩,២៥៧,៤៤៧ លានរៀល ត្រូវជា ៨.៤២% នៃផលិតផលក្នុងស្រុកសរុប គឺមានកំណើន៩.៨% ធៀបនឹងច្បាប់ឆ្នាំ២០១៨[17]។

**រូបភាពទី១៖ បង្ហាញពីសូចនាករថវិកាជាតិសំខាន់ៗពីឆ្នាំ២០១៧ ដល់២០១៩**

| សូចនាករថវិកា | ២០១៧ | | ២០១៨ | ២០១៩ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | ច្បាប់ |
| ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស) | ១៨,៥១ | ២០,២៤ | ១៨,៧១ | ១៩,២៨ |
| *ចំណូលចរន្ត (%ផសស)* | ១៨,៣៥ | ២០,០៨ | ១៨,៥៣ | ១៩,១០ |
| ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (%ផសស) | ២៣,៥៧ | ២៣,៤៥ | ២៤,៥៤ | ២៤,៧២ |
| *ចំណាយចរន្ត (%ផសស)* | ១៥,៣៧ | ១៥,៦៦ | ១៦,០៥ | ១៦,៣០ |
| អតិរេកចរន្ត (%ផសស) | ២,៩៧ | ៤,៤៣ | ២,៤៨ | ២,៨១ |
| ឱនភាពសរុប (%ផសស) | -៥,០៥ | -៣,២១ | -៥,៨៣ | -៥,៤៤ |

*ប្រភព៖ នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា/ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ/ថវិកាជាតិឆ្នាំ២០១៨*

[17] ថវិកាសង្ខេបសម្រាប់ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ទំព័រ១០-១៣

# ជំពូកទី៣

# ស្ថានភាពគោល

# នយោបាយរូបិយវត្ថុនៅ

# កម្ពុជា

## ៣.១. ស្ថានភាពទូទៅនៃគោលនយោបាយរូបិយវត្ថុនៅកម្ពុជា

**ប្រអប់ទី៦៖ ស្ថានភាពទូទៅនៃគោលនយោបាយរូបិយវត្ថុនៅកម្ពុជា**

### ១. ស្ថានភាពអតិផរណា

អតិផរណាជាមធ្យមមានអត្រា២.៥% ក្នុងឆ្នាំ២០១៨ ដែលជាកម្រិតមួយទាបជាងការព្យាករណ៍កាលពីដើមឆ្នាំ(៣%) និងអតិផរណាឆ្នាំ២០១៧(២.៩%)។ អត្រាទាបនេះបណ្តាលមកពីការថយល្បឿននៃកំណើនថ្លៃម្ហូបអាហារ ខណៈដែលអតិផរណាក្រុមទំនិញ និងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈមានកម្រិតខ្ពស់ជាងឆ្នាំមុន ហើយអតិផរណាស្នូលបន្តមានស្ថិរភាពក្នុងកម្រិតទាប ដែលឆ្លុះបញ្ចាំងពីស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្រោមបរិការណ៍ស្ថិរភាពនយោបាយ និងការអនុវត្តគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុមានភាពសមស្រប។

### ២. ស្ថានភាពអត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាព ជាមធ្យមប្រមាណ ៤,០៥៥រៀលក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ ធៀបនឹងឆ្នាំមុន(៤,០៥១) ដោយសារតែការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ក្នុងបរិបទដែលតម្លៃប្រាក់រៀលបានប្រែប្រួលបន្តិចបន្តួចទៅតាមកត្តារដូវកាលជាពិសេសកំណើនតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធមានការកើនឡើង២៥%ក្នុងរយៈពេល១០ខែដើមឆ្នាំ២០១៩។ ជាក់ស្តែងធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដោយបញ្ចេញប្រាក់រៀលស្មើ២ដងនៃទំហំទឹកប្រាក់ក្នុងឆ្នាំ២០១៨។

នៅក្នុងឆ្នាំ ២០១៨ អត្រាប្តូរប្រាក់រៀលធៀបដុល្លារអាមេរិករក្សាបាននូវអត្រាបានក្នុងរង្វង់៤,០៥០រៀលក្នុងមួយដុល្លារអាមេរិក ដែលបណ្តាលមកពីបរិការណ៍ដែលរូបិយបណ្ណរបស់ប្រទេសមួយចំនួនកំពុងទទួលរងសម្ពាធពីការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលអាមេរិក និងដោយសារការផ្គត់ផ្គង់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជាមានកម្រិតស្របនឹងការកើនឡើងតម្រូវការប្រាក់រៀល តាមរយៈការទិញកសិផល និងការបង់ពន្ធ។

### ៣. ស្ថានភាពរូបិយវត្ថុ

#### ៣.១. រូបិយវត្ថុទូទៅ(M2)

រូបិយវត្ថុទូទៅ(M2)មានកំណើន២៤.២% ខ្ពស់ជាងកំណើនឆ្នាំមុនបន្តិច(២៣.៨%) និងកំណើនមធ្យមប្រចាំឆ្នាំក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ(២២%)។ កំណើនរូបិយវត្ថុទូទៅ នេះបន្តមានកម្រិតសមស្របនឹងការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច និងមិនបានបណ្តាលឲ្យមានសម្ពាធលើអត្រាអតិផរណា និងអត្រាប្តូរប្រាក់ឡើយ។ សមាសធាតុរូបិយវត្ថុទូទៅសំខាន់ៗដែលបានជំរុញកំណើនរូបិយវត្ថុទូទៅរួមមាន កំណើនប្រាក់

បញ្ញើជារូបិយបណ្ណ និងរូបិយវត្ថុក្នុងចរាចរណ៍។ កំណើនរូបិយវត្ថុទូទៅបាននាំឲ្យភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (M2/GDP) កើនដល់៧៨.៥% ធៀបនឹង៧៣%នៅក្នុងឆ្នាំ២០១៧ ដែលបង្ហាញថាវិស័យហិរញ្ញវត្ថុបន្តរួមចំណែកកាន់តែសកម្មក្នុងការគាំទ្រកំណើនសកម្មភាពសេដ្ឋកិច្ច។

## រូបភាពទី២៖ បង្ហាញពីស្ថានភាពនៃរូបិយវត្ថុទូទៅ និងដុល្លាររូបនីយកម្ម




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើជារូបិយបណ្ណបានកើនឡើងក្នុងអត្រា២៦.៨% ខ្ពស់ជាងកំណើនឆ្នាំមុន(២៣.៦%) ដោយសារការបន្តកើនឡើងនៃប្រាក់ចំណូល និងសន្សំរបស់សាធារណជន ការបន្តទទួលបានលំហូរមូលធនចូលមកក្នុងសេដ្ឋកិច្ច និងជំនឿទុកចិត្តលើប្រព័ន្ធធនាគារ។ ប្រាក់បញ្ញើជារូបិយបណ្ណធៀបនឹងរូបិយវត្ថុទូទៅមានរហូតដល់ទៅ ៨៤% ហើយប្រាក់បញ្ញើរូបិយបណ្ណធៀបនឹង ប្រាក់បញ្ញើសរុបមានរហូតដល់ទៅ ៩៥% ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដែលឆ្លុះបញ្ចាំងពីស្ថានភាពដុល្លាររូបនីយកម្មនៅកម្ពុជា គឺមានកម្រិតខ្ពស់នៅឡើយ។ ទន្ទឹមនេះ ប្រាក់រៀលក្នុងចរាចរណ៍មានកំណើន១៤.១% ទាបជាងកំណើននៅឆ្នាំមុន(២៨.៧%)។

**រូបភាពទី៣៖ បង្ហាញពីស្ថានភាពបញ្ញើជារៀល និងឥណទានចំពោះវិស័យឯកជន**







ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

បច្ចុប្បន្ន រូបិយវត្ថុក្នុងចរាចរណ៍មានចំនួន១០.២ទ្រីលានរៀល(២.៥ ប៊ីលានដុល្លារអាមេរិក) និងមានសមាមាត្រ ១១.៥% ធៀបនឹងរូបិយវត្ថុទូទៅ និង១០.៣% ធៀបនឹងផលិតផលក្នុងស្រុកសរុប។ ជាមួយគ្នានេះ ប្រាក់បញ្ញើជារៀលមានកំណើន៩% ធៀបនឹងកំណើន១៧.៥% នៅឆ្នាំមុន។

**៣.២. ស្ថានភាពសន្ទនីយភាព**

សន្ទនីយភាពក្នុងប្រព័ន្ធធនាគារបន្តស្ថិតក្នុងកម្រិតខ្ពស់។ សន្ទនីយភាពលើសជាដុល្លារអាមេរិកមានចំនួន១.៩ប៊ីលានដុល្លារអាមេរិក(កើន៨%) ស្មើនឹង៦១% នៃប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក។ សន្ទនីយភាពលើសជារៀលមានចំនួន១.៤ទ្រីលានរៀល(ថយ៥%) ស្មើនឹង២.៥ដងនៃប្រាក់បម្រុងកាតព្វកិច្ចជារៀល។

*ប្រភព៖ របាយការណ៍ប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់ធនាគារជាតិនៃកម្ពុជា*

## ៣.២. ការអនុវត្តគោលនយោបាយរូបិយវត្ថុនៅកម្ពុជា

បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជាគឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ សំដៅរក្សាស្ថិរភាពថ្លៃ ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រកបដោយភាពប្រុងប្រយ័ត្ន អតិផរណាត្រូវបានគ្រប់គ្រងឱ្យស្ថិតក្នុងកម្រិតទាប ក្នុងអត្រាមធ្យមប្រចាំឆ្នាំតិចជាង ៥% ដែលសមស្របសម្រាប់

ប្រទេសកំពុងអភិវឌ្ឍន៍។ ទោះជាយ៉ាងនេះក្ដី ក្នុងបរិការណ៍សេដ្ឋកិច្ចដែលមានកម្រិតដុល្លារូបនីយកម្មខ្ពស់ ប្រសិទ្ធភាពនៃការអនុវត្តគោល នយោបាយរូបិយវត្ថុនៅមានកម្រិតនៅឡើយ ស្របពេលដែលធនាគារជាតិនៃកម្ពុជាពុំមាន លទ្ធភាពគ្រប់គ្រាន់ក្នុងការដើរតួជាអ្នកឱ្យខ្ចីចុងក្រោយ[18] ។ល។

មុខងារចម្បងរបស់ធនាគារជាតិនៃកម្ពុជាមាន៥យ៉ាងសំខាន់ៗ៖

១. ដើរតួនាទីជាអាជ្ញាធររូបិយវត្ថុ និងអនុវត្តគោលនយោបាយរូបិយវត្ថុ

២. ដើរតួនាទីជាអ្នកបោះពុម្ពផ្សាយរូបិយបណ្ណជាតិផ្ដាច់មុខ

៣. ដើរតួនាទីជាអាជ្ញាធរត្រួតពិនិត្យ និងដាក់បទបញ្ញត្តិលើប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ

៤. ត្រួតពិនិត្យលើប្រព័ន្ធទូទាត់នានានៅក្នុងប្រទេសកម្ពុជា

៥. គ្រប់គ្រងទុនបម្រុងអន្តរជាតិរបស់ប្រទេស។

### ២.២.១. គណៈកម្មការអភិវឌ្ឍន៍គោលនយោបាយរូបិយវត្ថុ

គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ ជាគណៈកម្មាធិការគោលនយោបាយកម្រិតខ្ពស់របស់ធនាគារជាតិនៃកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីវាយតម្លៃការអភិវឌ្ឍន៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធ្វើសេចក្ដីសម្រេចចិត្តលើគោលនយោបាយរូបិយវត្ថុ ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃ។ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុជួបប្រជុំជាប្រចាំត្រីមាស ពោលគឺ ៤ដងក្នុងមួយឆ្នាំ។ មុនកិច្ចប្រជុំចាប់ផ្ដើម ក្រុមលេខាធិការដ្ឋាន រួមមានអ្នកសេដ្ឋកិច្ច និងមន្ត្រីបុគ្គលិកផ្សេងទៀតពីនាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ និងនាយកដ្ឋានស្ថិតិ នឹងរៀបចំរបាយការណ៍វិភាគលំអិតសម្រាប់គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ។ យោងតាមរបាយការណ៍នេះ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុនឹងពិភាក្សា និងវាយតម្លៃទិដ្ឋភាពផ្សេងគ្នានៃសេដ្ឋកិច្ច ដោយផ្ដោតលើការអភិវឌ្ឍន៍សេដ្ឋកិច្ច និងហិរញ្ញវត្ថុគន្លឹះៗ គិតចាប់ពីកិច្ចប្រជុំចុងក្រោយ។ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុនឹងប្រមូលផ្ដុំការវិភាគនេះ គួបផ្សំនឹងការវិនិច្ឆ័យ និងការព្យាករណ៍ពីអ្វីដែលនឹងអាចកើតមានក្នុងសេដ្ឋកិច្ច និងថ្លៃក្នុងអំឡុងពេលខាងមុខ រួចធ្វើការសម្រេចចិត្តលើជម្រើសគោលនយោបាយរូបិយវត្ថុ ដើម្បីធានាស្ថិរភាពថ្លៃរយៈពេលវែង។

### ២.២.២. ឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

បច្ចុប្បន្ន ឧបករណ៍គោលនយោបាយ រូបិយវត្ថុដែលត្រូវបានប្រើប្រាស់ដើម្បីរក្សាស្ថិរភាពថ្លៃ គឺការដាក់អត្រាប្រាក់បម្រុងកាតព្វកិច្ច និង ការធ្វើអន្តរាគមន៍លើទីផ្សារប្ដូរប្រាក់ ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍន៍ ឧបករណ៍គោលនយោបាយរូបិយវត្ថុបន្ថែម ដើម្បីពង្រឹងប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ

[18] ទិដ្ឋភាពទូទៅគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា

តាមរយៈការចេញផ្សាយមូលបត្រអាចជួញដូរបាន ការអភិវឌ្ឍន៍ទីផ្សារអន្តរធនាគារនិងទីផ្សារ រូបិយវត្ថុ និងការពង្រឹងការប្រើប្រាស់ប្រាក់រៀល។

### ២.២.២.១. គោលនយោបាយអត្រាប្តូរប្រាក់

នៅក្នុងសេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់ ការកំណត់គោលដៅ និងអនុវត្តគោលនយោបាយរូបិយវត្ថុ ត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន។ ម្យ៉ាង ប្រសិទ្ធភាពនៃគោលនយោបាយរូបិយវត្ថុនឹងត្រូវបានកាត់បន្ថយ ដោយសារតែអាជ្ញាធររូបិយវត្ថុមិនមានឥទ្ធិពលគ្រប់គ្រាន់ក្នុងការគ្រប់គ្រងបរិមាណរូបិយបណ្ណបរទេស។ អាស្រ័យហេតុនេះ គោលនយោបាយអត្រាប្តូរប្រាក់បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចបាននូវគោលដៅសេដ្ឋកិច្ចតាម រយៈគោលនយោបាយរូបិយវត្ថុ (Mardy Lut, and Pahlaj Moolio, ២០១៥)។ គោលនយោបាយអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា គឺជាឧបករណ៍នយោបាយមួយរបស់គោលនយោបាយរូបិយវត្ថុ ដែលមានគោលដៅចម្បងគឺរក្សាស្ថិរភាពថ្លៃ។ ជាមួយនឹងការអនុវត្តរបបអត្រាប្តូរប្រាក់ អណ្តែតមានការគ្រប់គ្រង ធនាគារជាតិនឹងធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ ដើម្បីគ្រប់គ្រង និងរក្សាស្ថិរភាព អត្រាប្តូរប្រាក់ ទៅតាមគោលដៅដែលបានកំណត់។

ការរក្សាតម្លៃប្រាក់រៀល តាមរយៈការរក្សាបាននូវស្ថិរភាពអត្រាប្តូរប្រាក់ វាពិតជាសំខាន់នៅក្នុងការរក្សា និងគ្រប់គ្រងកម្រិតនៃអត្រាអតិផរណា។ ធនាគារជាតិនៃកម្ពុជាបានចូលរួមទិញ លក់រូបិយបណ្ណអន្តរជាតិ ជាពិសេសប្រាក់ដុល្លារអាមេរិក ក្នុងគោលដៅរក្សាស្ថិរភាពអត្រាប្តូរប្រាក់។ នៅពេលដែលប្រាក់រៀលមានការធ្លាក់ថ្លៃខ្លាំង នោះធនាគារជាតិនឹងដាក់ដេញថ្លៃប្រាក់ដុល្លារពីទុនបម្រុងអន្តរជាតិរបស់ខ្លួន ដើម្បីប្រមូលយកប្រាក់រៀលមកវិញ។ ប៉ុន្តែ ការទិញប្រាក់រៀលបែបនេះ នឹងជះឥទ្ធិពលពីរយ៉ាងទៅលើធនាគារជាតិ។ ទីមួយ គឺកាត់បន្ថយទុនបម្រុងរបស់ធនាគារជាតិ។ ទីពីរ គឺធ្វើឲ្យបរិមាណរូបិយបណ្ណក្នុងស្រុក(ប្រាក់រៀល) ដែលកំពុងចរាចរណ៍ធ្លាក់ចុះ ប៉ុន្តែប្រាក់ដុល្លារនឹងកើនឡើង ដែលវានឹងជះឥទ្ធិពលលើប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុរបស់ធនាគារជាតិ (បណ្ឌិត ហង់ ជួនណារ៉ុន, ម៉ាក្រូសេដ្ឋកិច្ច ទំព័រ១៨៩-១៩០,២០០៩)។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៨ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកពីគ្រឹះស្ថានធនាគារពាណិជ្ជ និងអាជីវករប្តូរប្រាក់សរុបប្រមាណ ៨៧៥ លានដុល្លារអាមេរិក ថយចុះ៩%បើធៀបនឹងឆ្នាំមុន។ ការថយចុះនេះ បណ្តាលមកពីកត្តាពីរយ៉ាង។ ទី១៖ គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុមានលទ្ធភាពទទួលបានប្រាក់រៀលតាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(LPCO) និងទី២៖ ការថមថយនៃអតិរេកសមតុល្យជញ្ជីងទូទាត់[19]។

[19] របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា ទំព័រ៣២

ជាទូទៅ ធនាគារជាតិមានជម្រើសពីរ នៅក្នុងការអន្តរាគមន៍លើទីផ្សារប្តូរប្រាក់[20]៖

១. ការធ្វើអន្តរាគមន៍លើរូបិយវត្ថុបរទេសដោយមិនបោះផ្សាយមូលបត្រ(Unsterilized foreign exchange intervention) ៖ ការទិញប្រាក់រៀល ដោយប្រាក់ដុល្លារ នឹងធ្វើឲ្យបរិមាណរូបិយបណ្ណរៀលនៅក្នុងទីផ្សារមានការធ្លាក់ចុះ ហើយតម្លៃនឹងកើនឡើង ប៉ុន្តែទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនឹងធ្លាក់ចុះ ឬថ្លយមកវិញ។

២. ការធ្វើអន្តរាគមន៍លើរូបិយវត្ថុបរទេសដោយបោះផ្សាយមូលបត្រ(Sterilized intervention)៖ ដោយមិនចង់ឲ្យប៉ះពាល់ដល់មូលដ្ឋានរូបិយវត្ថុ នោះធនាគារជាតិនឹងប្រើប្រាស់ប្រតិបត្តិការបើកចំហរ ដើម្បីប្រមូលយកប្រាក់រៀល ឬប្រាក់ដុល្លារវិញ តាមរយៈការបោះមូលបត្រលក់ ឬទិញ។

**រូបភាពទី៤៖ បង្ហាញពីការឡើងចុះនៃអត្រាប្តូរប្រាក់ និងអត្រាអតិផរណាពីឆ្នាំ២០១០ ដល់ ២០២០**




*ប្រភព៖ អគ្គនាយកដ្ឋានថវិកា/ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(MEF)*

ផ្អែកតាមការព្យាករណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ការព្យាករណ៍មុនវិបត្តិកូវីដ១៩) អត្រាអតិផរណាមធ្យមប្រចាំឆ្នាំត្រូវបានប៉ាន់ស្មានថាស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងអត្រា២.៩%ក្នុងឆ្នាំ២០២០

[20] សូមស្វែងយល់បន្ថែម៖ Kim Abildgren, Economics, Sterilised and Non-Sterilised Intervention in the Foreign-Exchange Market,[http://www.nationalbanken.dk/en/publications/Documents/2005/04/2005_MON1_061_ster.pdf]

ស្របនឹងការរំពឹងទុកនៃការកើនឡើងខ្លះនូវថ្លៃម្ហូបអាហារជាពិសេសថ្លៃអង្ករ ខណៈដែលថ្លៃប្រេងលើទីផ្សារអន្តរជាតិត្រូវបានរំពឹងថានឹងបន្តធ្លាក់ចុះដែលអាចបណ្តាលមកពីឥទ្ធិពលនៃសង្គ្រាមពាណិជ្ជកម្ម។

អត្រាប្តូរប្រាក់រៀល គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់៤,០៥៤រៀលក្នុងមួយដុល្លារអាមេរិកនៅក្នុងឆ្នាំ ២០២០ ដោយសារតែស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀលតាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ[21]។

### ២.២.២.២. ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ចជាឧបករណ៍គោលនយោបាយរូបិយវត្ថុមួយ ដែលធនាគារជាតិនៃកម្ពុជាប្រើដើម្បីគ្រប់គ្រងល្បឿនកំណើនឥណទាន ។ បច្ចុប្បន្ន អត្រាប្រាក់បម្រុងកាតព្វកិច្ចសម្រាប់រូបិយបណ្ណបរទេស (ជាពិសេស ប្រាក់ដុល្លារអាមេរិក) និងរូបិយវត្ថុជាតិ ត្រូវបានកំណត់ផ្សេងគ្នា ។ អត្រាប្រាក់បម្រុងកាតព្វកិច្ចត្រូវបានបន្តរក្សាក្នុងកម្រិត៨% ចំពោះប្រាក់បញ្ញើជារៀល និង១២.៥% ចំពោះប្រាក់បញ្ញើជារូបិយបណ្ណ និងកម្ចីអនិវាសជន[22]។ ការបន្តរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀលទាបជាងដុល្លារអាមេរិក គឺដើម្បីលើកទឹកចិត្ត និងជំរុញឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកេណ្ឌប្រមូលប្រាក់បញ្ញើ និងផ្តល់ឥណទានជារៀលបន្ថែម ខណៈដែលតម្រូវការប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចមានការកើនឡើងជាលំដាប់។ គួររំលឹកថា ចាប់ពីខែកញ្ញា ឆ្នាំ២០១៨កន្លងមក ធនាគារជាតិនៃកម្ពុជា បានសម្រេចបញ្ឈប់ការផ្តល់ការប្រាក់លើប្រាក់បម្រុងកាតព្វកិច្ចជារូបិយបណ្ណ[23]។

ទោះបីជាយ៉ាងណាក៏ដោយ ទុនបម្រុងកាតព្វកិច្ចនៅតែមិនអាចគ្រប់គ្រងបានទាំងស្រុងទេ នូវបរិមាណរូបិយវត្ថុនៅក្នុងទីផ្សារ ជាពិសេសប្រាក់ដុល្លារអាមេរិក។ ដោយសារតែ លំហូរចេញ និងចូលនៃមូលធន ត្រូវបានធ្វើឡើងដោយសេរី តាមរយៈការវិនិយោគពីបរទេស និងប្រាក់បញ្ញើបរទេស។ ដរាបណា អត្រាការប្រាក់នៅក្នុងស្រុកនៅតែមានកម្រិតខ្ពស់ជាងនៅបរទេស នោះលំហូរចូលនៃប្រាក់ដុល្លារនៅតែបន្តមាន ដែលធនាគារជាតិនៃកម្ពុជា នៅតែមិនអាចគ្រប់គ្រងបរិមាណទាំងអស់នោះបាន។

---

[21] ថវិកាសង្ខេបឆ្នាំ២០២០

[22] គោលនយោបាយអត្រាប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា [https://www.nbc.org.kh/monetary_policy/exchange_rate_policy.php] (អានថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០)

[23] គួរបញ្ជាក់ថា មុនការសម្រេចបញ្ឈប់ការផ្តល់ការប្រាក់នេះ ធនាគារជាតិនៃកម្ពុជាតែងតែផ្តល់ការប្រាក់ទៅលើចំណែក៤.៥% នៃប្រាក់បម្រុងកាតព្វកិច្ចជារូបិយប័ណ្ណ១២.៥% ខណៈដែលប្រាក់បម្រុងកាតព្វកិច្ចជារៀល(៨%) មិនទទួលបានការប្រាក់ទេ។

**២.២.២.៣. កម្ចីអប្បហារ**

(បណ្ឌិត ហង់ ជួនណារ៉ុន, ម៉ាក្រូសេដ្ឋកិច្ច ទំព័រ១៩២, ២០០៩) កម្ចីអប្បហារជាប្រាក់រៀល នៅមិនទាន់ក្លាយជាឧបករណ៍គោលនយោបាយរូបិយវត្ថុនៅកម្ពុជានៅឡើយទេ ដោយសារតែបរិមាណសាច់ប្រាក់រៀលរបស់ធនាគារពាណិជ្ជនៅកម្ពុជានៅសល់ទំនេរច្រើនលើសលប់ ដោយមិនចាំបាច់ត្រូវខ្ចីពីធនាគារជាតិនៃកម្ពុជាឡើយ។

**២.២.២.៤. មូលបត្រអាចជួញដូរបានរបស់ធនាគារជាតិនៃកម្ពុជា**(NCD)

ទីផ្សារមូលបត្រនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ ដោយសារតែ (១) គ្មានឧបករណ៍អាចជួញដូរបាន ដូចជាមូលបត្ររដ្ឋាភិបាលដែលអាចបើកផ្លូវសម្រាប់ការអភិវឌ្ឍទីផ្សារអន្តរធនាគារ (២) អវត្តមានអ្នកកំណត់ទីផ្សារ និងបណ្តាញអន្តរការីយកម្មនានា និង (៣) គ្មានអត្រាការប្រាក់គោលសម្រាប់មូលដ្ឋានក្នុងការកំណត់ថ្លៃមូលបត្រនាពេលបោះផ្សាយ។

ដោយសារហេតុផលខាងលើ ធនាគារជាតិនៃកម្ពុជា (NBC) បានបង្កើតគម្រោងការអភិវឌ្ឍទីផ្សារអន្តរធនាគារ ដោយបានចេញប្រកាសលេខ ធ.៥.០១០-១៨៣ ប្រ.ក ស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០។ គម្រោងការអភិវឌ្ឍទីផ្សារអន្តរធនាគារមានបំណងដូចជា៖

១. បង្កើនការឲ្យខ្ចីអន្តរធនាគារប្រកបដោយសុវត្ថិភាព។

២. បង្កើតឲ្យមានឧបករណ៍មានប្រសិទ្ធភាពបន្ថែម សម្រាប់អនុវត្តនយោបាយរូបិយវត្ថុ និងនយោបាយអត្រាប្តូរប្រាក់។

៣. បែងចែកឡើងវិញនូវប្រភពហិរញ្ញវត្ថុក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងបង្កើន និងពង្រីកអន្តរការិយកម្មហិរញ្ញវត្ថុ។

៤. កាត់បន្ថយការផ្តេកផ្តួលរបស់ធនាគារលើប្រភពទុនអំពីអ្នកដាក់ប្រាក់បញ្ញើ ដើម្បីបំពេញតម្រូវការសន្ទនីយភាពបណ្តោះអាសន្នរយៈពេលខ្លី និងមធ្យម។

៥. ឆ្លើយតបទៅនឹងតម្រូវការទីផ្សារហិរញ្ញវត្ថុក្នុងការ៖

- វិនិយោគសន្ទនីយភាពដែលនៅសល់ទំនេររយៈពេលខ្លី។ ធនាគារភាគច្រើនមិនមានជម្រើសផ្សេងក្នុងការវិនិយោគសន្ទនីយភាពដែលលើសពីការប្រើប្រាស់របស់ខ្លួនឡើយ។
- កាត់បន្ថយហានិភ័យពាក់ព័ន្ធនឹងការគ្រប់គ្រងសន្ទនីយភាព និងការផ្តល់ប្រាក់កម្ចីអន្តរធនាគារ។

បន្ទាប់ពីបានរៀបចំអស់រយៈពេល ៣ ឆ្នាំមក NBC បានសម្រេចដាក់ឲ្យដំណើរការជាផ្លូវការនូវគម្រោងអភិវឌ្ឍន៍ទីផ្សារអន្តរធនាគាររបស់ខ្លួននៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៣។

មូលបត្រអាចជួញដូរបាន (NCD) គឺជាបណ្ណបំណុលរយៈពេលខ្លីមានការប្រាក់ ដែលចេញដោយធនាគារជាតិនៃកម្ពុជា។ មូលបត្រនេះត្រូវបានចេញផ្សាយជាប្រាក់រៀល (KHR) និងប្រាក់ដុល្លារអាមេរិក (USD) ដើម្បីជួយ ដល់បណ្ដាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុវិនិយោគនូវសន្ទនីយភាពរយៈពេលខ្លីរបស់ខ្លួន។ តម្លៃនាមចារឹកអប្បបរមា គឺ ៥០,០០០ ដុល្លារអាមេរិក ឬ ២០០,០០០,០០០ រៀល។ កាលវសាននៃ KHR-NCD មានចាប់ពី ២ សប្ដាហ៍ ដល់ ១ឆ្នាំ ចំណែកឯ USD-NCD វិញ មានកាលវសានចាប់ពី ២ សប្ដាហ៍ ដល់ ៦ខែ។ អត្រាការប្រាក់របស់ NCD ត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា ហើយប្រែប្រួលជារៀងរាល់ថ្ងៃទៅតាមលក្ខខណ្ឌទីផ្សារ។

**ប្រអប់ទី៧៖ NCD ត្រូវបានដាក់ឲ្យទិញ-លក់រវាងគ្រឹះស្ថានហិរញ្ញវត្ថុ**

NCDត្រូវបានបោះផ្សាយលក់ដោយធនាគារជាតិនៃកម្ពុជាកាលពីចុងឆ្នាំ ២០១៣ ប៉ុន្តែវាត្រូវបានជួញដូរផ្ទាល់ពីគ្រឹះស្ថានហិរញ្ញវត្ថុមកធនាគារជាតិជារៀងរាល់ថ្ងៃ។ NCD គឺជាលិខិតបញ្ជាក់ពីប្រាក់បញ្ញើដែលបោះផ្សាយដោយធនាគារកណ្ដាលដើម្បីលក់ទៅឲ្យគ្រឹះស្ថានហិរញ្ញវត្ថុក្នុងរយៈពេលកំណត់ណាមួយហើយគ្រឹះស្ថានដែលទិញ NCD ពីធនាគារជាតិអាចយកទៅលក់បន្តឲ្យគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត (វាស្រដៀងនឹងការលក់មូលបត្របំណុលដែរ ដែលអ្នកកាន់កាប់ NCD នឹងទទួលបានការប្រាក់ក្នុងអំឡុងពេលនៃការកាន់កាប់)។ លោកស្រី ជា សិរី អគ្គនាយិកាធនាគារជាតិនៃកម្ពុជាប្រាប់ភ្នំពេញប៉ុស្តិ៍តាមអ៊ីមែលថាតម្រូវការ NCD កំពុងកើនឡើងនៅទីផ្សារហិរញ្ញវត្ថុកម្ពុជាដូច្នេះ NBC ត្រូវតែផ្លាស់ប្ដូរយន្តការខ្លះៗដើម្បីអភិវឌ្ឍឲ្យមានការជួញដូររវាងស្ថាប័នហិរញ្ញវត្ថុ និងស្ថាប័នដូចគ្នា។ លោកស្រីបន្ថែមថាការផ្លាស់ប្ដូរការលក់ NCD ប្រចាំសប្ដាហ៍នឹងជំរុញធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុឲ្យទិញ NCD កាន់តែខ្លាំងជាងមុន។

លោកស្រីថ្លែងថា៖ «ការចេញផ្សាយមូលបត្រអាចជួញដូរបានប្រចាំសប្ដាហ៍នឹងជំរុញគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឲ្យធ្វើផែនការ និងគ្រប់គ្រងសាច់ប្រាក់របស់ពួកគេកាន់តែមានប្រសិទ្ធភាព និងរួមចំណែកក្នុងការអភិវឌ្ឍទីផ្សារអន្តរធនាគារនៅប្រទេសកម្ពុជាផងដែរ»។ លោកស្រី ជា សិរី ពន្យល់ថាការចេញផ្សាយ NCD ប្រចាំសប្ដាហ៍នឹងផ្ដល់ប្រយោជន៍ជាច្រើនដូចជាការកាត់បន្ថយការចំណាយប្រតិបត្តិការ និងការជួញដូរ NCD របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុការបន្ថយចំណាយប្រតិបត្តិការរបស់ធនាគារជាតិនៃកម្ពុជា និងជំរុញឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើការជួញដូរជាមួយគ្នាទៅវិញទៅមកក្នុងអំឡុងពេលដែល NBC មិន

ចេញផ្សាយ NCD។ មិនត្រឹមតែប៉ុណ្ណោះ NBC អាចដឹកនាំប្រតិបត្តិការរូបិយវត្ថុមានប្រសិទ្ធភាពកាន់តែប្រសើរ តាមរយៈការចាក់បញ្ចូលសាច់ប្រាក់លើទីផ្សារនៅពេលមានកង្វះខាត ឬការកាត់បន្ថយនៅពេលមានភាពលើស។

តាមរបាយការណ៍ប្រចាំឆ្នាំ ២០១៥ របស់ធនាគារជាតិនៃកម្ពុជា NBC បានបោះផ្សាយលក់ NCD ចំនួន ១២៣៤ គិតត្រឹមឆ្នាំ ២០១៥ ក្នុងចំណោមនោះ NCD ចំនួន ២៨៩ ត្រូវបានបោះផ្សាយជាប្រាក់រៀល និង ៩៤៥ ផ្សេងទៀតបោះផ្សាយជាលុយដុល្លារ។ NCD ចំនួន ២៨៩ មានតម្លៃជាទឹកប្រាក់ស្មើនឹង ៧៣៦,៦ លានដុល្លារ ខណៈ NCD ចំនួន ៩៤៥ មានតម្លៃជាទឹកប្រាក់ ៣,៧ ពាន់លានដុល្លារ។ នៅត្រឹមខែទី ៤ ឆ្នាំ ២០១៥ NBC ក៏បានកាត់បន្ថយចំនួនកំណត់ការវិនិយោគអប្បបរមាលើតម្លៃ NCD ដែលបោះផ្សាយបន្ទាប់ពី ២ ពាន់លានរៀលក្នុងមួយ NCD មកនៅត្រឹម ២០០ លានរៀលខណៈអប្បបរមាលើ NCD គិតជាប្រាក់ដុល្លារត្រូវបានបន្ទាប់ពី ៥០០ ០០០ ដុល្លារមកនៅត្រឹម ៥០ ០០០ ដុល្លារវិញ។ ការធ្វើបែបនេះគឺដើម្បីជំរុញឲ្យមានការជួញដូរ NCD ឲ្យបានកាន់តែច្រើន។[...]

ប្រភព៖ អត្ថបទដោយ ហ៊ា គីមសាយ,ភ្នំពេញប៉ុស្តិ៍, ចេញផ្សាយថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៦,[https://www.post khmer.com / author/%E1%9E%A0%E1%9F%8A-%E1%9E%82%E1%9E%B8%E1%9E%98%E1%9E%9F%E1%9E%B6%E1%9E%99/2054]

# ជំពូកទី៤
# ការសិក្សាលើការវិភាគ
# និងបកស្រាយលទ្ធផល

# ការសិក្សាលើការវិភាគ និងបកស្រាយលទ្ធផល

## ៤.១. លទ្ធផលនៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាកាន់តែស៊ីជម្រៅទៅលើភាពសំខាន់ និងឥទ្ធិពលឧបករណ៍គោលនយោបាយរូបិយវត្ថុទៅលើប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនាពេលកន្លងមក ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេល១ទសវត្សរ៍ចុងក្រោយនេះ យើងនឹងធ្វើការវិភាគទិន្នន័យមួយចំនួនដែលពាក់ព័ន្ធដូចខាងក្រោម៖

Model ដែលត្រូវសិក្សា៖

$$GDP_t = \beta_0 + \beta_1 M2_t + \beta_2 EXC_t + \varepsilon_t$$

ដែល៖

$GDP_t$ ជាផលិតផលក្នុងស្រុកសរុបពិតនៅពេលt គិតជាលានដុល្លារអាមេរិក

$M2_t$ ជាបរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) នៅពេលt គិតជាលានដុល្លារអាមេរិក

$EXC_t$ ជាអត្រាប្តូរប្រាក់នៅពេលt គិតជារៀល/ដុល្លារអាមេរិក

នៅក្នុងការសិក្សានេះ បរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) និងអត្រាប្តូរប្រាក់(EXC) ត្រូវបានសន្មត់ថាមានឥទ្ធិពលលើផលិតផលក្នុងស្រុកសរុប(GDP) របស់កម្ពុជាក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ។

**តារាងទី២៖ ទិន្នន័យដែលត្រូវធ្វើការសិក្សា និងវិភាគពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៨**

| ឆ្នាំ | GDP | M2 | EXC |
|---|---|---|---|
| 2009 | 10,609.615 | 3,898.553 | 4,139.333 |
| 2010 | 11,242.275 | 4,677.432 | 4,184.917 |
| 2011 | 12,037.056 | 5,013.062 | 4,058.500 |
| 2012 | 12,917.367 | 7,032.912 | 4,033.000 |
| 2013 | 13,867.655 | 8,579.913 | 4,027.250 |
| 2014 | 14,858.162 | 11,253.660 | 4,037.500 |
| 2015 | 15,903.595 | 13,068.552 | 4,067.750 |
| 2016 | 17,021.771 | 15,848.226 | 4,058.695 |
| 2017 | 18,215.854 | 19,555.073 | 4,050.580 |
| 2018 | 19,581.672 | 24,743.604 | 4,051.167 |

*ប្រភពទិន្នន័យ៖ ធនាគារពិភពលោក/ World Bank*[24]

[24] https://data.worldbank.org/country/cambodia មើលថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០

**តារាងទី៣៖ ការពិពណ៌នាស្ថិតិ**/Descriptive Statistics

| | N | Minimum | Maximum | Mean | Std. Deviation |
|---|---|---|---|---|---|
| GDP | 10 | 10609.62 | 19581.67 | 14625.5022 | 3030.39582 |
| M2 | 10 | 3898.55 | 24743.60 | 11367.0987 | 6963.55837 |
| EXC | 10 | 4027.25 | 4184.92 | 4070.8692 | 50.83216 |
| Valid N (listwise) | 10 | | | | |

តាមតារាងស្ថិតិខាងលើនេះ បានបង្ហាញពីអថេរចំនួន៣ ដូចជា ផលិតផលពិតក្នុងស្រុកសរុប(GDP) បរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) និងអត្រាប្តូរប្រាក់(EXC)។ នៅក្នុងចន្លោះឆ្នាំ ២០០៩ ដល់២០១៨ គេសង្កេតឃើញថា ផលិតផលក្នុងស្រុកសរុប(GDP)របស់កម្ពុជាមានកម្រិតទាបបំផុតចំនួន ១០,៦០៩.៦២លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០០៩ និងខ្ពស់បំផុតចំនួន ១៩,៥៨១.៦៧លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨។ បើគិតជាមធ្យមមានចំនួន ១៤,៦២៥.៥០២លានដុល្លារអាមេរិក ដែលមានន័យថា កំណើនផលិតផលក្នុងស្រុកសរុប(GDP)ក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះមាននិន្នាការកើនឡើង។

**តារាងទី៤៖ ការបង្ហាញពីទំនាក់ទំនងនៃអថេរនីមួយៗ**/Correlations

| | | GDP | M2 | EXC |
|---|---|---|---|---|
| GDP | Pearson Correlation | 1 | .986** | -.536 |
| | Sig. (1-tailed) | | .000 | .055 |
| | N | 10 | 10 | 10 |
| M2 | Pearson Correlation | .986** | 1 | -.438 |
| | Sig. (1-tailed) | .000 | | .103 |
| | N | 10 | 10 | 10 |
| EXC | Pearson Correlation | -.536 | -.438 | 1 |
| | Sig. (1-tailed) | .055 | .103 | |
| | N | 10 | 10 | 10 |

**. Correlation is significant at the 0.01 level (1-tailed).

តាមតារាង Correlations ខាងលើបានបង្ហាញថា បរិមាណផ្គត់ផ្គង់រូបិយវត្ថុM2 នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ មានទំនាក់ទំនងវិជ្ជមានខ្លាំង ជាមួយនឹងផលិតផលក្នុងស្រុកសរុប(GDP)នៅក្នុងប្រទេសកម្ពុជានៅកម្រិតហានិភ័យ ១% (1-side) ដែលមានន័យថា ប្រសិនបើបរិមាណផ្គត់ផ្គង់រូបិយវត្ថុមានការកើនឡើងនោះ ផលិតផលក្នុងស្រុកសរុបនឹងកើនឡើងដែរ ឬផ្ទុយមកវិញ។ ចំណែកឯ អត្រាប្តូរប្រាក់(EXC)វិញ គឺមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងផលិតផលក្នុងស្រុកសរុប(GDP) នៅក្នុងកម្រិតហានិភ័យ១០%(1-side) ដែលមានន័យថា ប្រសិនបើអត្រាប្តូរប្រាក់មានការធ្លាក់ចុះនោះ កំណើនសេដ្ឋកិច្ចនឹងកើនឡើង ឬផ្ទុយមកវិញ។

**តារាងទី៥៖ បង្ហាញពី** Model Summary

| Model | R | R Square | Adjusted R Square | Std. Error of the Estimate |
|---|---|---|---|---|
| 1 | .992[a] | .985 | .980 | 427.12193 |

a. Predictors: (Constant), EXC, M2

R-squared គឺជារង្វាស់ស្ថិតិមួយដែលបង្ហាញពីភាពស៊ីគ្នានៃទិន្នន័យដែលយកមកសិក្សាដែលមានទម្រង់ជាបន្ទាត់។ វាត្រូវបានបង្ហាញជាទម្រង់ភាគរយ (0% ដល់១០០%)នៃការប្រែប្រួលរបស់អថេរមិនឯករាជ្យដែលត្រូវបានបកស្រាយនៅក្នុង Linear Regression Model។ តម្លៃ0% គឺបង្ហាញថាអថេរមិនឯករាជ្យមិនត្រូវបានពន្យល់ដោយអថេរឯករាជ្យនោះទេ។ ផ្ទុយទៅវិញ ប្រសិនបើតម្លៃនោះ កាន់តែខិតជិត១០០% នោះមានន័យថា អថេរដែលយកមកសិក្សាគឺមានភាពស៊ីសង្វាក់គ្នាល្អ។

នៅក្នុងការវិភាគ multiple correlation coefficient មេគុណR ត្រូវបានគេប្រើដើម្បីពិនិត្យមើលពីទំនាក់ទំនង និងគុណភាពលទ្ធផលនៃការព្យាករណ៍។ តម្លៃR គឺស្ថិតនៅក្នុងចន្លោះ (-1) និង (+1)។ ប្រសិនបើវាស្ថិតនៅក្បែរ0 នោះមានន័យថា ទំនាក់ទំនងរវាងអថេរឯករាជ្យ និងមិនឯករាជ្យគឺមានកម្រិតខ្សោយ ឬគ្មានទំនាក់ទំនង ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើវាកាន់តែខិតជិត១ នោះវាបង្ហាញពីទំនាក់ទំនងខ្លាំងរវាងដែលបានចូលរួមនៅក្នុងការវិភាគ ឬលទ្ធផលនៃការព្យាករណ៍នឹងមានភាពល្អប្រសើរ។

តាមតារាងវិភាគខាងលើយើងឃើញថា៖

- តម្លៃR ៖ តាមតារាងខាងលើ តម្លៃR ស្មើនឹង០.៩៩២ ដែលមានន័យថា មានទំនាក់ទំនងខ្លាំងរវាងអថេរនីមួយៗដែលចូលរួមនៅក្នុងModel។

- តម្លៃR-Square ៖ តាមលទ្ធផលខាងលើ R-Square គឺមានតម្លៃ៩៨.៥% ដែលមានន័យថា ផលិតផលក្នុងស្រុកសរុប (GDP) មានការប្រែប្រួលរហូតដល់ទៅ៩៨.៥% ដោយសារតែការផ្គត់ផ្គង់រូបិយវត្ថុ (M2) និងអត្រាប្តូរប្រាក់(EXC) ដែលជាអថេរឯករាជ្យនៅរវាង១០ឆ្នាំចុងក្រោយនេះ ពោលគឺចាប់ពីឆ្នាំ ២០០៩ ដល់២០១៨ ឬមានន័យថា Model អាចពន្យល់បាន៩៨.៥%។

**តារាងទី៦៖ ការបង្ហាញពីតារាងANOVA[a]**

| Model | | Sum of Squares | df | Mean Square | F | Sig. |
|---|---|---|---|---|---|---|
| 1 | Regression | 81372657.368 | 2 | 40686328.684 | 223.020 | .000[b] |
| | Residual | 1277031.976 | 7 | 182433.139 | | |
| | Total | 82649689.344 | 9 | | | |

a. Dependent Variable: GDP

b. Predictors: (Constant), EXC, M2

តារាង ANOVA ត្រូវបានគេប្រើដើម្បីពិនិត្យមើលលទ្ធភាពនៃការទទួលយក Model ដែលយកមកសិក្សាដែលជាទូទៅ គេពិនិត្យលើតម្លៃ P-value ដែលមានតម្លៃតិចជាង៥%។

តាមតារាងANOVA បង្ហាញថា តម្លៃ P-value ស្មើនឹង0% ដែលមានកម្រិតតូចជាង៥% មានន័យថា Model ដែលយកមកសិក្សាគឺអាចទទួលយកបាន។

**តារាងទី៧៖ បង្ហាញពីការព្យាករណ៍/Coefficients[a]**

| Model | | Unstandardized Coefficients | | Standardized Coefficients | t | Sig. |
|---|---|---|---|---|---|---|
| | | B | Std. Error | Beta | | |
| 1 | (Constant) | 41194.902 | 12800.140 | | 3.218 | .015 |
| | M2 | .404 | .023 | .929 | 17.780 | .000 |
| | EXC | -7.656 | 3.116 | -.128 | -2.457 | .044 |

a. Dependent Variable: GDP

គេបានសមីការព្យាករណ៍៖

$$GDP_t = 41{,}194.902 + 0.404M2_t - 7.656EXC_t + \varepsilon_t$$
$$SE: \quad 12{,}800.140 \quad 0.023 \quad 3.116$$
$$n = 10, R^2 = 0.985$$

## ៤.២. ការបកស្រាយលទ្ធផល

តាមការព្យាករណ៍បានបង្ហាញថា GDP មានតម្លៃថេរចំនួន៤១,១៩៤.៩០២ឯកតា បើទោះបីជាគ្មានកត្តាទាំងពីរនេះចូលរួមក៏ដោយ។

ការផ្គត់ផ្គង់រូបិយវត្ថុ(M2) មានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច(GDP) នៅត្រង់ហានិភ័យ១% ពោលគឺប្រសិនបើការផ្គត់ផ្គង់រូបិយវត្ថុកើន១លានដុល្លារអាមេរិក នោះសេដ្ឋកិច្ចកម្ពុជានឹងកើន ០.៤០៤លានដុល្លារអាមេរិក។ ការរកឃើញនេះ គឺស្របទៅនឹងលទ្ធផលនៃការស្រាវជ្រាវរបស់ (Mardy Lut & Pahlaj Moolio, 2015) ដែលរកឃើញថា បរិមាណផ្គត់ផ្គង់រូបិយវត្ថុ(M2) គឺពិតជាមានទំនាក់ទំនងវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ចកម្ពុជា។ ជាការពិតការផ្គត់ផ្គង់រូបិយវត្ថុក្នុងទីផ្សារ វានឹងជួយជម្រុញសកម្មភាពសេដ្ឋកិច្ច តាមរយៈការកើនឡើងនៃតម្រូវការ ដែលនឹងធ្វើឲ្យការផ្គត់ផ្គង់ និងការផលិតមានការកើនឡើងដែរ។ ប្រជាជនចាប់ផ្ដើមមានចំណូលច្រើនជាងមុន ហើយកាន់កាប់រូបិយវត្ថុក្នុងដៃក៏មានការកើនឡើង ដែលនឹងធ្វើឲ្យល្បឿនរង្វិលរូបិយវត្ថុក៏កើនឡើងលឿនជាងមុន នោះសកម្មភាពសេដ្ឋកិច្ចក៏មានភាពមមាញឹកជាងមុនដែរ។ តាមដំណើរការទាំងអស់នេះ នឹងឈានទៅដល់គោលដៅនៃការបង្កើនកំណើនសេដ្ឋកិច្ច និងបង្កើតការងារជាអតិបរមា[25]។

ចំពោះ អត្រាប្តូរប្រាក់(EXC)វិញ គឺមានឥទ្ធិពលអវិជ្ជមានទៅលើកំណើនសេដ្ឋកិច្ច(GDP) នៅត្រង់ហានិភ័យ៥% ពោលគឺប្រសិនបើអត្រាប្តូរប្រាក់(EXC)មានការកើនឡើង១ឯកតា ឬមានន័យថា ប្រាក់ដុល្លារអាមេរិកមានតម្រូវការកើនឡើង ដែលធ្វើឲ្យប្រាក់រៀលមានការធ្លាក់ថ្លៃ១ឯកតាបើធៀបជាមួយនឹងប្រាក់ដុល្លារអាមេរិក នោះសេដ្ឋកិច្ច(GDP)នឹងធ្លាក់ចុះ៧.៦៥៦ឯកតា។ នោះដោយសារតែប្រទេសកម្ពុជា ជាប្រទេសដែលមានសេដ្ឋកិច្ចមានលក្ខណៈដុល្លាររូបនីយកម្មខ្ពស់នៅឡើយ ដែលការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកនឹងជះឥទ្ធិពលអវិជ្ជមានចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា ហើយដែលប៉ះពាល់ជាងគេនោះគឺអ្នកដែលកំពុងតែកាន់កាប់ និងចាយវាយជាប្រាក់រៀល ជាពិសេសដែលរកចំណូលបានជាប្រាក់រៀល ដែលនឹងធ្វើឲ្យតម្លៃរបស់វានឹងថយជាង

[25] The Federal Open Market Committee. Function Conducting Monetary Policy (២០១៦). [https://www.federalreserve.gov/aboutthefed/files/pf_3.pdf]

មុន ជាហេតុធ្វើឲ្យការចាយវាយ តម្រូវការក្នុងស្រុក រួមទាំងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកថមថយល្បឿន។ ការរកឃើញនេះ គឺស្របទៅនឹងលទ្ធផលនៃការស្រាវជ្រាវ(Monorith Sean, ២០១៩) ដែលបានបង្ហាញថាការកើនឡើងនៃតម្លៃប្រាក់ដុល្លារអាមេរិកនឹងធ្វើឲ្យមានការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ចកម្ពុជា៕

# សេចក្តីសន្និដ្ឋាន
# និងការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថា ជាប្រទេសមួយដែលមានការអភិវឌ្ឍលឿនមួយនៅក្នុងពិភពលោក ជាមួយនឹងល្បឿនសេដ្ឋកិច្ចក្នុងរង្វង់អត្រាប្រមាណជា៧%ក្នុងមួយឆ្នាំ។ យោងតាមការចុះផ្សាយរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) បានបង្ហាញថា នៅក្នុងឆ្នាំ២០១៨ កំណើនសេដ្ឋកិច្ចកម្ពុជាមានអត្រា៧.៥% និងតាមការព្យាករណ៍សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១៩មានអត្រា៧% ហើយនៅឆ្នាំ២០២០ខាងមុខនេះ នឹងធ្លាក់មកត្រឹមអត្រា៦.៨%(របាយការណ៍មុនការកើតវិបត្តិកូវីដ១៩)។ នៅក្នុងរបាយការណ៍ដដែលនោះក៏បានបង្ហាញពីអត្រាអតិផរណាចំនួន២.២%ផងដែរ នៅក្នុងឆ្នាំ២០១៩ និង២.៥% នៅឆ្នាំ២០២០[26]។ ដោយឡែក លទ្ធផលនៃកំណើនសេដ្ឋកិច្ចដែលទទួលបាននាពេលកន្លងមកនេះ គឺមានភាពសមស្របទៅនឹងគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ដែលនឹងធ្វើការកែប្រែប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសមានចំណូលកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៥០[27]។ សេដ្ឋកិច្ចកម្ពុជាត្រូវបានទ្រទ្រង់ដោយសសរស្តម្ភចំនួន៤ ទី១ គឺវិស័យកាត់ដេរ ទី២ វិស័យសំណង់ ទី៣ គឺវិស័យកសិកម្ម និងចុងក្រោយគឺវិស័យទេសចរណ៍។ នៅក្នុងចំណោមវិស័យទាំងនោះ វិស័យកាត់ដេរ (កាត់ដេរសម្លៀកបំពាក់ និងស្បែកជើង) បានដើរតួនាទីសំខាន់ជាងគេ ដែលបានស្រូបយកកម្លាំងពលកម្មច្រើនជាង១លាននាក់ ដែលក្នុងនោះមានស្ត្រីជាង៨០% និងមានយុវជន ដែលមានចន្លោះអាយុពី១៥ ដល់ ៣០ឆ្នាំប្រមាណជាង៨០%ផងដែរ[28]នាពេលបច្ចុប្បន្ននេះ ដែលភាគច្រើនលើសលុបគឺជាយុវជន។ លើសពីនេះ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើងមានចំនួន២ភាគ៣នៃការនាំចេញសរុបរបស់កម្ពុជា ដែលមានការកើនឡើងពី៨.៤% នៅឆ្នាំ២០១៧ ទៅ១៧.៧%នៅក្នុងឆ្នាំ២០១៨[29] ដែលបានរុញកំណើនសេដ្ឋកិច្ចកម្ពុជាឲ្យស្ទុះទៅមុខយ៉ាងឆាប់រហ័ស

---

[26] ស្ថានភាពសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០១៩, ចុះផ្សាយដោយADB, https://www.adb.org/countries/cambodia/economy (អានថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩)

[27] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ (ភាសាខ្មែរ) របស់រដ្ឋាភិបាលកម្ពុជាhttps://data.opendevelopmentmekong.net/dataset/45181125-a82b-4e36-af52-1bb23a22d31e/resource/303b4d36-a41b-4721-9545-3a3ed9933e1b/download/68a763e1-7e2f-405c-81e7-4872665deda5.pdf (អានថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩)

[28] Living conditions of garment and footwear sector workers in Cambodia, ចុះផ្សាយដោយ ILO, Issue 8 | December 2018, as per latest developments. https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok /documents/publication/wcms_663043.pdf (អានថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២០)

[29] Recent Economic Developments and Outlook (WB, English) 2019 http://documents.worldbank.org/curated/en/843251556908260855/Cambodia-Economic-Update-Recent-Economic-Developments-and-Outlook

ពីមួយឆ្នាំ ទៅមួយឆ្នាំ។ បរិមាណតម្រូវការក្នុងស្រុកបានកើនឡើងដោយសារតែកំណើនប្រាក់បៀវត្សរ៍កើនឡើងកាន់តែខ្ពស់ជាងមុន និងវិនិយោគទុនសាធារណៈច្រើនជាងមុន ជាមួយនឹងការកើនឡើងផ្នែកហិរញ្ញវត្ថុ ដែលដើរតួជាការលើកទឹកចិត្ត។ បរិមាណតម្រូវការដ៏ច្រើនពីក្រៅប្រទេស បានជំរុញដល់ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង ដែលបានបង្កើនចំណូលបាន ១៦,១ភាគរយ ក្នុងកំឡុងឆមាសទី១ ឆ្នាំ ២០១៨។

ដោយឡែក ការរីកចម្រើនទាំងអស់នេះ សុទ្ធតែមានការគាំទ្រយ៉ាងសកម្មពីឧបករណ៍គោលនយោបាយ រូបិយវត្ថុរបស់ធនាគារជាតិនៃកម្ពុជា តាមរយៈការរក្សាបាននូវកម្រិតអត្រាអតិផរណាក្រោម៥% និងការរក្សាបាននូវស្ថេរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ជាមធ្យមប្រមាណ៤០,៥០រៀលក្នុងមួយដុល្លារអាមេរិកនៅក្នុង១ឆ្នាំ។

